

អារម្ភកថា | FOREWORD

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈចាត់ទុកឧស្សាហកម្មភាពយន្តជាផ្នែកសំខាន់មួយនៃយុទ្ធសាស្ត្រអភិវឌ្ឍសេដ្ឋកិច្ច និងវប្បធម៌របស់ខ្លួន។ បន្ទាប់ពីការរាតត្បាតនៃជំងឺប៉ុន្មានឆ្នាំនេះ រាជរដ្ឋាភិបាលកម្ពុជាសង្ឃឹមថានឹងស្វាគមន៍សមិទ្ធិករភាពយន្តទាំងឡាយមកចូលរួម **CIFF** ឡើងវិញ ដែលជាព្រឹត្តិការណ៍មួយជួយផ្សព្វផ្សាយពីកម្ពុជាក្នុងនាមជាគោលដៅដ៏ទាក់ទាញសម្រាប់ការថតភាពយន្តបរទេស ក៏ដូចជាផ្សព្វផ្សាយពីខ្សែភាពយន្តកម្ពុជាផងដែរ។

ជាច្រើនឆ្នាំកន្លងមកនេះ កំណើនចំណាប់អារម្មណ៍របស់ទស្សនិកជនខ្មែរចំពោះព្រឹត្តិការណ៍ភាពយន្តប្រចាំឆ្នាំមួយនេះ ជាការនាំផ្លូវឱ្យឧស្សាហកម្មភាពយន្តកាន់តែរឹងមាំ ដោយមានការកើនឡើងនៃចំនួនរោងភាពយន្ត និងផ្ទាំងសំពត់សរហូតដល់១០០នៅក្នុងឆ្នាំនេះ។

CIFF បានក្លាយជាស្ពានដ៏សំខាន់មួយទៅកាន់ពិភពលោក និងជាវេទិកាអប់រំមួយតាមរយៈខ្សែភាពយន្ត។ **CIFF** តែងតែអនុលោមតាមច្បាប់កម្មសិទ្ធិបញ្ញាអន្តរជាតិ និងច្បាប់កម្ពុជាយ៉ាងខ្ជាប់ខ្ជួន ដែលជាមូលដ្ឋានគ្រឹះនៃកម្លាំងរុញច្រានគំនិតច្នៃប្រឌិត ធ្វើឱ្យមាននិរន្តរភាពដល់ឧស្សាហកម្មនៃភាពច្នៃប្រឌិតថ្មីៗ។

ជាទីបញ្ចប់ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សូមថ្លែងអំណរគុណសមិទ្ធិករភាពយន្ត អ្នករៀបចំកម្មវិធី ដៃគូសហការ និងអ្នកស្ម័គ្រចិត្តដែលបន្តអភិវឌ្ឍ **CIFF** ដែលជាកត្តាលីករនៃភាពច្នៃប្រឌិតថ្មីនៅកម្ពុជា។

ខ្ញុំសង្ឃឹមថា ទស្សនិកជននឹងរីករាយស្វែងយល់អំពីសាច់រឿង និងរូបភាពថ្មីៗអំពីកម្ពុជា និងប្រទេសផ្សេងទៀតនៅលើពិភពលោកដែលនឹងត្រូវបង្ហាញនៅក្នុងមហោស្រពនេះ។

បណ្ឌិតសភាចារ្យ ភឿង សកុណា
រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

Greetings,

The Ministry of Culture and Fine Arts wishes to welcome Cambodia and international filmmakers to the 12th CIFF.

The Royal Government of Cambodia considers the film industry as an essential part of its strategy of cultural and economic development. The growing interest in cinema from the Cambodian audience for this annual film celebration leads the way toward a healthier and stronger film industry in the Kingdom.

CIFF is an essential component for the promotion of Cambodian talents, a platform for education through film, and an opportunity to explore the world. The diversity of the program offers a chance to explore again our past, witness the world today, and imagine innovations of tomorrow.

The Ministry of Culture and Fine Arts extends its gratitude to Matt Dillon the director of “City of Ghosts”, a film made in Cambodia in 2001, who supports CIFF as Patron. I wish to thank all filmmakers, organisers, partners and volunteers who continue to develop CIFF as a catalyst of creativity in Cambodia.

I am convinced that this 12th CIFF will be a successful event once again and provide opportunities for all generations to share stories and images from Cambodia and the rest of the world.

Dr. Phoeurng Sackona
Minister of Culture and Fine Arts



“ ការថតរឿង «ទីក្រុងខ្មោច» នៅក្នុងប្រទេសកម្ពុជា គឺជាព្រឹត្តិការណ៍ដ៏សំខាន់មួយក្នុងជីវិតខ្ញុំ។ ប្រទេសកម្ពុជាគឺជាកន្លែងវិសេសមួយសម្រាប់ខ្ញុំ។ ទីនេះជាដែនដីដ៏មានជីជាតិសម្រាប់ភាពច្នៃប្រឌិត។ វាពិតជាអស្ចារ្យណាស់ដែលឃើញថាវិស័យភាពយន្តកម្ពុជាបានវិវឌ្ឍទៅជាឧស្សាហកម្មមួយជឿនលឿន។ ខ្ញុំទន្ទឹងរង់ចាំមើលថាតើសមិទ្ធិករភាពយន្តក្មេងៗទាំងអស់នេះនឹងមានអ្វីប្លែកនាពេលអនាគត។ **CIFF** ជាកម្មវិធីដ៏មានសារៈសំខាន់បំផុតសម្រាប់សមិទ្ធិករភាពយន្តកម្ពុជា និងសមិទ្ធិករភាពយន្តមកពីជុំវិញពិភពលោក ក៏ព្រោះតែនេះជាប្រភេទមហោស្រពដែលដើរតួយ៉ាងសំខាន់សម្រាប់ការអភិវឌ្ឍវិស័យភាពយន្ត។

ខ្ញុំពិតជារំភើបដែលក្លាយជាចំណែកមួយនៃមហោស្រពដ៏អស្ចារ្យមួយនេះ។ ”

- តារាហូលីវូដ **Matt Dillon,** ប្រធានកិត្តិយស **CIFF** លើកទី១២

Matt Dillon ជាអ្នកដឹកនាំរឿងបែបរន្ធត់ដ៏ល្បីល្បាញមួយមានចំណងជើងថា «ទីក្រុងខ្មោច» ដែលរឿងនេះត្រូវបានថតនៅក្នុងប្រទេសកម្ពុជា។ ស្នាដៃនៅក្នុងវិស័យភាពយន្តដ៏គួរឱ្យស្ញើចសរសើររបស់ **Matt Dillon** រួមមានការសម្តែងដ៏គួរឱ្យចាប់អារម្មណ៍នៅក្នុងភាពយន្តហូលីវូដដូចជារឿង **Something About Mary** និង រឿង **Wild Things** ក៏ដូចជារឿង **Crash** ជាភាពយន្តឯករាជ្យដែលទទួលបានការកោតសរសើរខ្លាំង ហើយរឿងនេះធ្វើឱ្យលោកទទួលបានពានរង្វាន់ **Independent Spirit Award** និងត្រូវបានជ្រើសរើសជាភាពយន្តសម្រាប់ការប្រកួតយកពានរង្វាន់ **Golden Globe** និងពានរង្វាន់អូស្កា ក្នុងនាមជាតួរងល្អបំផុតទៀតផង។ លោកក៏ទទួលបានការគាំទ្រផងដែរចំពោះការអត្ថាធិប្បាយក្នុងរឿងរបស់ **Jack Kerouac** ដែលមានចំណងជើងថា **On the Road** ដោយលោកត្រូវបានជ្រើសរើសឱ្យចូលរួមប្រកួតយកពានរង្វាន់ **Grammy** សម្រាប់ផ្នែក **Best Spoken Word Album**។ នៅក្នុងឆ្នាំ២០១៥ លោកបានសម្តែងនៅរដូវកាលទីមួយនៃស៊េរីកម្មវិធី **Wayward Pines** របស់ទូរទស្សន៍ **Fox** ដែលលោកត្រូវជ្រើសរើសសម្រាប់ការប្រកួតយកពានរង្វាន់ **Saturn Award**។

“ **Cambodia is a very special place to me. It is such a fertile ground for creativity. It's really great to see that it's really developed into a thriving film industry. I'm really looking forward to see what these young filmmakers come up with in the future.**

The CIFF is incredibly important for Cambodian filmmakers and filmmakers throughout the world, these are the types of festivals that are so important for the development of cinema.

I am thrilled of be a part of this wonderful film festival. ”

- MATT DILLON, PATRON of the 12th CIFF

Director of the famous noir thriller based in Cambodia, The City of Ghosts. Dillon's impressive filmography includes notable performances in Hollywood blockbusters such as Something About Mary and Wild Things, as well as critically acclaimed independent films like Crash, for which he won an Independent Spirit Award and was nominated for a Golden Globe and Academy Award for Best Supporting Actor. He has also been recognized for his narration of Jack Kerouac's On the Road, earning a Grammy nomination for Best Spoken Word Album. In 2015, he starred in the first season of the FOX television series Wayward Pines, for which he was nominated for a Saturn Award.

រូបថតដោយ៖ Roland Neveu

STORIES IN CAMBODIA

ទីក្រុងខ្មោច
CITY OF GHOSTS

ដោយ ម៉ាត ឌីលលិន, សហរដ្ឋអាមេរិក/២០០២/១១៦ នាទី

by Matt Dillon, United States/2002/116 min

ជនឆបោកម្នាក់បានគេចខ្លួនទៅអាស៊ីអាគ្នេយ៍នៅពេលដែលក្បាច់បោកប្រាស់ខ្នាតអន្តរជាតិរបស់គេខុសពីអ្វីដែលគេគិត។ សង្ស័យថាគេកំពុងតែត្រូវបានបោកប្រាស់ដោយគ្រូណែនាំជិតស្និតរបស់គេ គេក៏ចាកចេញទៅប្រទេសកម្ពុជាដើម្បីប្រាក់ចំណែករបស់គេ។ នៅទីនោះគេប្រទះបរិស្ថានយ៉ាងចម្លែកនិងមិនរួសរាយរាក់ទាក់ឡើយ ជាកន្លែងដែលសូម្បីតែជនបោកប្រាស់ដ៏ជំនាញក៏អាចនឹងជាប់អន្ទាក់បានដែរ។

A con man flees to Southeast Asia when an international scam he was involved in goes sour. Suspecting he's been double-crossed by his long-time mentor, he sets off to Cambodia for his promised cut. What he finds there is a mysterious and hostile environment where even the most polished criminal can end up on deadly ground.

ទេពហត្ថា
THE PERFECT MOTION

ដឹកនាំដោយហ្សាវីយេ ដឺឡូហ្សាន, បារាំង-កម្ពុជា/៨៦នាទី/២០២៣

by Xavier de Lauzanne, France,Cambodia/86 min/2023

ដំណើរនៃរបាំព្រះរាជទ្រព្យ និងរបាំបុរាណខ្មែរ សិល្បៈរាប់ពាន់ឆ្នាំ និងនិមិត្តសញ្ញានៃអត្តសញ្ញាណ ដែលត្រូវបានស្តារឡើងវិញ ភាពយន្តដែលរួមបញ្ចូលនូវអារម្មណ៍ ទឹកមុខ និងសម្រស់នៃកាយវិការរបស់ «ទេពហត្ថា» ។ ភាពយន្តដែលនិយាយពីចលនា និងសាច់រឿងពីក្រោយគ្រប់ចលនាទាំងនោះ។

The odyssey of the Cambodian Royal Ballet and the Khmer classical dance. A millenary art and the symbol of a restored identity. A movie that captures history, emotion, expression and the beauty of hand gestures. A movie about movement and the story behind it.

អូណូដា៖ មួយម៉ឺនរាត្រីនៅក្នុងព្រៃ
ONODA: 10,000 NIGHTS IN THE JUNGLE

ដោយ អរធើ ហារ៉ារី, បារាំង/ជប៉ុន/កម្ពុជា/២០២១/១៦៥ នាទី

by Arthur Harari, France/Japan/Cambodia/2021/165 min

នៅប្រទេសជប៉ុនក្នុងឆ្នាំ១៩៤៤។ ហ៊ីរូ អូណូដា មានវ័យ២២ឆ្នាំ ជាបុគ្គលមួយរូបដែលបានហ្វឹកហាត់ក្នុងការងារស៊ើបការណ៍,បានរកឃើញទស្សនវិជ្ជាមួយដែលផ្ទុយទៅហ្នឹងប្រយោគផ្លូវការ៖ មានរឿងអ្វីកើតឡើងក៏ដោយ មិនត្រូវធ្វើអត្តឃាតឡើយ, បេសកកម្មនេះគឺសំខាន់ជាងអ្វីៗទាំងអស់។ គេមិនព្រមទទួលយកទេថាសង្គ្រាមលោកលើកទី២ត្រូវបានបញ្ចប់ហើយ, អូណូដាក៏បន្តប្រយុទ្ធនៅលើកោះដាច់ស្រយាលមួយនៅប្រទេសហ្វីលីពីនរហូតដល់ឆ្នាំ១៩៧៤។

Japan, 1944. Trained for intelligence work, Hiroo Onoda, 22 years old, discovers a philosophy contrary to the official line : no suicide, stay alive whatever happens, the mission is more important than anything else. Refusing to believe that World War II ended, Onoda continued to fight on a remote Philippine island until 1974.

អំណោយស្នេហ៍ថ្ងៃណាត់ជួប
WISHING LOLLIPOP

ដោយ អ៊ុន ប៊ុនធឿន, កម្ពុជា/២០២៣/១២៥ នាទី

by Un Bunthouern, Cambodia/2023/125 min

នាយខាយជាបុគ្គលិកផ្នែកលក់ម្នាក់ដែលព្យាយាមទិញខុនដូមួយយូនីតពីម្ចាស់ឈ្មោះនរាក្នុងគោលបំណងរកចំណូលដើម្បីព្យាបាលជំងឺម្តាយរបស់គេ។ ជីវិតរបស់គេប្រែប្រួលទៅជាខ្មៅងងឹតនិងនឹកស្មានមិនដល់នៅពេលដែលគេស្លាប់ ហើយព្រលឹងរបស់គេក៏ចូលសណ្ឋិតខ្លួនរបស់នរា១ខែមុនគេស្លាប់។

Kay, a salesperson at a condominium, tries to purchase back a condo unit from Norea in order to make enough profit to pay for his mother's hospital fee. His life takes a dark and twisting turn when he dies and his soul goes on to possess Norea's body one month prior to his death.

អ្នកការពារដៃឆៅ
THE GUARDIAN (PATRON SAINT)

ដោយ **ជីមមី ហិនដឺសុន,** កម្ពុជា/២០២៣/១០១នាទី

by Jimmy Henderson, Cambodia/2023/101 min

កៅ រ៉ាន់ ជាបុរសពោះម៉ាយ និងជាអ្នកប្រដាល់មិនជាបើម្នាក់ ដែលប្រើកណ្តាប់ដៃ ដើម្បីចិញ្ចឹមកូនស្រីឈ្មោះកូកូ។ គេតែងតែមានបញ្ហាជាមួយឪពុកក្មេក ឈ្មោះឡៅ យេ ដែលចង់បានសិទ្ធិមើលថែចៅ។ ពេលកូកូស្រាប់តែបាត់ខ្លួន កៅ រ៉ាន់ បានតាមរកក្នុងបណ្តាញជួញដូរមនុស្ស ហើយគេនឹងធ្វើគ្រប់យ៉ាងដើម្បីជួយកូកូ។

Gao Ran is a widowed, underdog boxer who throws fights in order to raise his daughter, Coco, while often tangling with his father in law, Lao Ye, who wants custody. When Coco suddenly goes missing, Gao's unrelenting search unearths a human trafficking network where he will stop at nothing to save Coco once and for all, and he won't be treading lightly.

តក់ៗពេញបំពង់
LITTLE BY LITTLE

ដោយ សាមូអ៊ែល ឌីអាស ហ្វីណាន់ដេហ្ស, កម្ពុជា/២០២២/២៨ នាទី

by Samuel Díaz Fernández, Cambodia/2022/28 min

ជោគវាសនានាំឲ្យចរិយានិងបញ្ញាដែលជាមិត្តពីកុមារភាពជួបគ្នាវិញម្តងទៀត។ ពួកគេមានក្តីស្រមៃដ៏ធំធេងជាមួយគ្នាក្នុងទីក្រុងភ្នំពេញ។ ស្របពេលដែលពួកគេសន្សំប្រាក់ដើម្បីអនាគត ចរិយានិងបញ្ញាពឹងពាក់លើគ្នាទៅវិញទៅមករួមទាំងមិត្តភក្តិថ្លង់របស់គេ កុសល បង្ហាញឲ្យឃើញថាក្តីស្រឡាញ់និងការប្រឹងប្រែងនាំយើងឲ្យបន្តដំណើរទៅមុខគ្រប់រដូវកាលនៃជីវិតពិតមែន។

A fateful encounter reconnects childhood friends Chakriya and Panha. Together, they dream of bigger things in the big city: Phnom Penh. As they save for their future, Chakriya and Panha lean on each other and their deaf friend Kosal, proving that love and perseverance moves us through each season of life.

CAMBODIA IN SHORT 1

សុបិនរបស់ប្រជាជនកម្ពុជាម្នាក់
A CAMBODIAN NIGHT'S DREAM
ដោយ ហ្គីលាំ សួន, កម្ពុជា/២០២២/៣០នាទី
by Guillaume Suon, Cambodia/2022/30 min

ឆ្ងាយដាច់អាល័យ
FURTHER AND FURTHER AWAY
ដោយ លី ប៉ូឡែន, កម្ពុជា/២០២២/២៤នាទី
by Polen Ly, Cambodia/2022/24 min

បញ្ចុះតម្លៃ
THE HAUL
ដោយ រ៉ូប៊ីន ណារស៊ីសូ, កម្ពុជា/២០២២/១០នាទី
by Robin Narciso, Cambodia/2022/10min



បំណុល
THE DEBT
ដោយ រ៉ូប៊ីន ដាដ់ហ្វៀលដ៏, កម្ពុជា/២០២១/១២នាទី
by Robin Dudfield, Cambodia/2021/12 min

អាថ៌កំបាំងក្រោមកម្រាលព្រំ
SWEPT UNDER
ដោយ អ៊ីថាន ស៊ូ, សហរដ្ឋអាមេរិក/២០២២/១០នាទី
by Ethan Soo, United States/2022/10 min

CAMBODIA IN SHORT 2

ក្ដារចុច
THE KEYBOARD
ដោយ វង្ស បញ្ញាវ៉ែន, កម្ពុជា/២០២២/៧នាទី
by Panhavon Vong, Cambodia/2022/7 min

ពណ៌
THE COLOUR
ដោយ ចាន់ ពិសី, កម្ពុជា/២០២២/៩នាទី
by Pisey Chan, Cambodia/2022/9 min

ស្បែកមានដង្ហើម
SKIN CAN BREATHE
ដោយ ឡេង ឈាងគា, សហរដ្ឋអាមេរិក/២០២២/១១នាទី
by Chheangkea Ieng, United States/2022/11 min

ចាប់គូ
SPEED DATING
ដោយ ជីនផូល លី, ចក្រភពអង់គ្លេស/២០២២/១៣នាទី
by Jean-Paul Ly, United Kingdom/2022/13 min

ជីវិតបុគ្គលិក
WORK LIFE
ដោយ ខេវិន អ៊ុង, សហរដ្ឋអាមេរិក/២០២៣/១៣នាទី
by Kevin Ung, United States/2023/13 min

ពីក្រោយការពិត
THE TRUTH UNTOLD
ដោយ សេង ពេជ្រស្រីពៅ, កម្ពុជា/២០២២/២៨នាទី
by Seng Pichsreypov, Cambodia/2022/28 min

TRIBUTE TO HUOY KENG

Mr. Huoy Keng, producer of Sovannkiri film production

Mr. Huoy Keng was born in 1937 in the province of Kampot. Mr. Huoy Keng was the director of the famous Sovankiri film production in the 1960s and 1970s. Huoy Keng's Sovan Kiri film is the only Cambodian film studio that has produced more than 20 films, both traditional and modern. Huoy Keng is a filmmaker who likes to use the beast as the subject of certain films, and all of them are very popular with the public.

Additionally, during the war of the 1970s, Sovankiri was the first Cambodian filmmaker to seek foreign markets as domestic business collapsed with the flames of war in Cambodia.

Mr. Huoy Keng's famous films include **"Male Dove"**, **"I Love You So Much, I Hate You"**, **"Because I Love You"**, **"Neang Vimean Chan"**, **"Kray Thong, Crocodile Charavan"**, **"Neang Champa Thong"**, **"Surya Komar and Preah Neang Tep Thida"**, **"A daughter of Elephant King"**, **"Keo Nama"**, **"A girl with snake hair"** and **"Bopha Angkor"**.

លោកហួយ គឹង ចាងហ្វាងផលិតកម្មសុវណ្ណគិរីភាពយន្ត

លោកហួយ គឹង កើតនៅឆ្នាំ១៩៣៧ នៅខេត្តកំពត។ លោកហួយ គឹង ជាចាងហ្វាងផលិតកម្មសុវណ្ណគិរីភាពយន្ត ដ៏ល្បីល្បាញនៅទសវត្ស១៩៦០ និង ១៩៧០។ សុវណ្ណគិរីភាពយន្តរបស់លោកហួយ គឹង ជាស្ទូឌីយ៉ូភាពយន្តខ្មែរតែមួយគត់ ដែលបានផលិតបានច្រើនជាងគេរហូតដល់ប្រមាណ២០រឿង ទាំងខ្សែភាពយន្តបែបបុរាណ និង សម័យទំនើប។ លោកហួយ គឹង ជាផលិតករភាពយន្តម្នាក់ដែលនិយមយកសត្វសាហាវមកធ្វើជាប្រធានបទនៃការផលិតខ្សែភាពយន្តមួយចំនួន ហើយភាពយន្តទាំងអស់នោះសុទ្ធសឹងទទួលបានការគាំទ្រយ៉ាងខ្លាំងពីទស្សនិកជន។

បន្ថែមពីនេះ នៅសម័យសង្គ្រាមកាលពីទសវត្ស១៩៧០ សុវណ្ណគិរីភាពយន្ត ក៏ជាផលិតកម្មខ្មែរទី១ ដែលបានស្វែងរកទីផ្សារនៅក្រៅប្រទេស ខណៈសកម្មភាពក្នុងស្រុកបានស្រុតចុះដោយភ្លើងសង្គ្រាមនៅប្រទេសកម្ពុជា។

ស្នាដៃភាពយន្តល្បីៗរបស់លោកហួយ គឹង មាន ដូចជារឿង «លលកញីឈ្មោល» «ស្រឡាញ់ណាស់ស្អប់ណាស់» «ព្រោះតែស្រឡាញ់» «នាងវិមានចន្ទ» «ក្រៃថោងក្រពើឆារ៉ាវ៉ាន់» «នាងចំប៉ាថោង» «សុរិយន្តកុមារនិងព្រះនាងទេពធីតា» «ស្ដេចដំរីស» «នាងកែវណាម៉ា» «ធីតាសក់ពស់» និង «បុប្ផាអង្គរ» ជាដើម។

Photo: DR Bophana Center/CIFF

TRIBUTE TO HUOY KENG

ធីតាសក់ពស់
THE SNAKE GIRL

ដោយ ហួយ គឹង, កម្ពុជា/១៩៧៣/៨៧នាទី (ភាសាខ្មែរ និងមានអក្សរអង់គ្លេសរត់ពីក្រោម)
by Huoy Keng, Cambodia/1973/87 min (Khmer version with English subtitle)

ឡុង ចាប់ចិត្តស្រឡាញ់អូនស្រី ដែលជាធីតាសក់ពស់។ តាំងពីកើតមក នាងរស់នៅតែក្នុងរូងភ្នំ ដូច្នេះនាងចេះប្រើតែភាសាកាយវិការប៉ុណ្ណោះ។ ឪពុកម្ដាយធម៌របស់ឡុងព្យាយាមរកវិធីបំបែកនាងចេញពីឡុង ដោយសារការច្រណែនឈ្នានីស។ អូនស្រីក៏ត្រូវគេចាប់ខ្លួនដើម្បីធ្វើពិធីបូជាយញ្ញ...

Long falls in love with Onn Srey, a snake girl. Having lived in the cave since she was born, Onn Srey can only use body language for communication. Because of jealousy and ambition, Long's godparents try to find ways to separate him from Onn Srey and Onn Srey is arrested for sacrifice ceremony...

ពស់កេងកងចូលក្រុង
THE SNAKE GIRL DROPS IN

ដោយ ហួយ គឹង/១៩៧៤/៩០នាទី/ភាសាបារាំង និងមានអក្សរអង់គ្លេសរត់ពីក្រោម
by Huoy Keng, Taiwan/1974/90 min/French version with English subtitle

យុវតីម្នាក់ ត្រូវគេចាប់ខ្លួនចេញពីក្នុងព្រៃ។ នៅពេលគេដឹងថា នាងមានសក់ក្បាលជាពស់ គេក៏ថា នាងជាបិសាច។ ចៅកែមានចិត្តឃោរឃៅ បានធ្វើទារុណកម្មអមនុស្សធម៌មកលើនាង។ ពួកគេដេញតាមចាប់ខ្លួននាងអស់ពេលយ៉ាងយូរ។ ក្រោយមក នាងអាចរត់គេចចេញបាន ដោយមានជំនួយពីបុរសម្នាក់ ដែលមានចិត្តលើនាង។

A mysterious and wild girl is captured in the jungle. When we realize that she has snakes instead of hair, she is mistaken for a demon. The cruel clan chief wants to subject her to inhuman torture. Luckily she can count on one of her jailers, in love with her, to escape.

ក្រៃថោងក្រពើឆារ៉ាវ៉ាន់
THE CROCODILE MEN

ដោយ ហួយ គឹង, កម្ពុជា/១៩៧៤/៨៦នាទី (ភាសាខ្មែរ និងមានអក្សរអង់គ្លេសរត់ពីក្រោម)
by Huoy Keng, Cambodia/1974/86 min (Khmer version with English and Chinese subtitle)

ក្រៃថោង និងឆារ៉ាវ៉ាន់ ចង់រៀនមន្តវិជ្ជា ហើយក៏រកបានឥសីម្នាក់ដែលយល់ព្រមបង្រៀនសិល្បវិជ្ជាដល់ពួកគេ។ ដោយមិនស្ដាប់តាមបម្រាមគ្រូ ឆារ៉ាវ៉ាន់បានលួចរៀនមន្តប្រែកាឡាខ្លួនជាសត្វក្រពើ។

Kraithoang and Chharavan wish to learn magic and find a hermit who agrees to pass on his knowledge to them. Against the will of his master, Chharavan learns a magical formula from a manuscript kept in a temple that he is guarding and he transforms himself into crocodile.

ព្រះនាងចំប៉ាថោង
PRINCESS CHAMPA THONG

ដោយ ហួយ គឹង, កម្ពុជា/១៩៦៩/៩៤នាទី/ភាសាខ្មែរ
by Huoy Keng, Cambodia/1969/94 min (Khmer version)

ព្រះនាងចំប៉ាថោងជាបុត្រីស្ដេចនគរវៃស្សាលិ។ ព្រះនាងបានយកក្រពើមួយក្បាលចូលរាជវាំងធ្វើជាសត្វចិញ្ចឹម។ ប៉ុន្តែ ក្រពើនេះខុសពីក្រពើដទៃ ៖ វាធំឡើងៗ ហើយកាចសាហាវណាស់។ វាចាប់ផ្ដើមសម្លាប់មនុស្សដែលរស់នៅតាមមាត់ទន្លេ។ ប្រជានុរាស្ត្រដឹងថា ភាពចលាចលបានមកដល់ព្រះនគររបស់ពួកគេហើយ។

Princess Champa Thong is the daughter of the King of Vesali. She brings a crocodile to the Royal Palace, keeping it as a pet. But the crocodile is not like others: When it grows up, it gets bigger and bigger and becomes so ferocious that it starts to kill people living along the river. The people realize: A plague has come to their kingdom.

CROSS VIEWS ON OUR COMMON HISTORY

កម្មវិធីនេះគឺជាការមើលទៅលើសម័យកាលដ៏វឹកវរនៃប្រវត្តិសាស្ត្ររបស់យើងទាំងអស់គ្នា តាមរយៈភាពយន្តប្រឌិត ឬភាពយន្តឯកសារ។ ៧០ឆ្នាំបន្ទាប់ពីកម្ពុជាបានឯករាជ្យ កម្មវិធីនេះផ្ដល់នូវការពិចារណាលើភាពចលាចល និងការផ្លាស់ប្ដូរនៅក្នុងតំបន់ ចាប់ពីទសវត្សឆ្នាំ១៩៥០មក ដែលបង្ហាញតាមកញ្ចក់កាមេរ៉ារបស់អ្នកថតភាពយន្តសង្គ្រាម និងអ្នកថតភាពយន្តជាច្រើនទៀតដែលចោទសួរលើបញ្ហាសង្គ្រាម។
ការក្រឡេកមើលរឿងរ៉ាវពីអតីតកាលឡើងវិញ និងការស្វែងយល់ពីទស្សនៈខុសៗគ្នាអាចជាគន្លឹះមួយនៃការកសាងអនាគត។

The perspective on troubled periods of our History can change over time, through fictions or documentaries. 70 years after the Independence of Cambodia, this program offers different reflections on the turmoils and changes the region went through from the 50's through the lenses of war filmmakers and filmmakers questioning war.

Looking back at memories and understanding points of views can be a key to a wiser future.

កងអនុសេនាតូចទី ៣១៧
The 317th PLATOON

ដឹកនាំដោយ ដោយ ព្យែរ ស្ហ៊ីនដូហ្វ៊ែរ, បារាំង/១៩៦៤/១០០នាទី
by Pierre Schoendoerffer, France/1964/100 mins

នៅចុងបញ្ចប់នៃសង្គ្រាមបារាំង-ឥណ្ឌូចិន អនុសេនាតូចបារាំងមួយកងជាប់នៅខាងខ្សែត្រៀមរបស់សត្រូវ ព្យាយាមស្វែងរកទីសុវត្ថិភាព។

Near the end of the French-Indochinese War, a French platoon trapped behind enemy lines tries to reach safety.

អ្នកវាយស្គរក្ដាម
THE DRUMMER-CRAB

ដោយ ព្យែរ ស្ហ៊ីនដូហ្វ៊ែរ, បារាំង/១៩៧៧/១២០នាទី
by Pierre Schoendoerffer, France/1977/120mins

ទាហានជើងទឹកហៀបនឹងអស់ជីវិតម្នាក់ដែលពោរពេញទៅដោយវិប្បដិសារី កំពុងតាមរកមិត្តរួមការងារយូរអង្វែងរបស់គាត់នៅតាមដែនសមុទ្រដ៏ធំល្វឹងល្វើយ។

A dying mariner, full of regret, is looking for his longtime colleague somewhere on the high seas.

ប្រទេសបារាំងគឺជាមាតុភូមិរបស់យើង
FRANCE IS OUR MOTHER COUNTRY

ដោយ ប៉ាន់ រិទ្ធី, បារាំង-កម្ពុជា/២០១៥/៧៥នាទី

by **Rithy Panh**, France, Cambodia/2015/75min

ខ្សែភាពយន្តនេះបង្ហាញអំពីជំនួបបរាជ័យរវាងវប្បធម៌ពីរដែលនាំឱ្យអាណានិគមនិយមមួយពោរពេញដោយភាពហិង្សា ការជួបគ្នាមួយពេលដែលគួរតែអាចបញ្ចៀសបាននូវសង្គ្រាមរីករវ និងការបំផ្លិចបំផ្លាញ។ ភាពយន្តនេះប្រមូលផ្តុំដោយរូបភាពបណ្ណសារ ដែលត្រូវបានថតមួយផ្នែកធំនៅឥណ្ឌូចិន ក្នុងដើមសតវត្សទី២០រហូតដល់ការដួលរលំក្រុងបៀនឌៀនភូ។ វាជាការពិចារណាទៅលើពេលវេលា ការចងចាំ និងការមើលឃើញដោយប្រើរូបភាពភាពយន្ត។

A story of a failed encounter between two cultures, two sensitivities, two realms of imagination. An encounter which resulted in a colonization not exempt from brutality while it could have avoided wars, chaos and destruction. Primarily based on extracts of archive film shot mainly in Indochina in the early twentieth century until the fall of Dien Bien Phu, this film is a continuation of a cinematographic reflection about time, memory and looking.

អាណាចក្រពាក់កណ្ដាលខាងត្បូង
THE EMPIRE OF MID-SOUTH

ដោយ ហ្សាក់ ពែរ៉ាំង & អេរិក ដេរូ, បារាំង/២០១១/៨៦នាទី/ភាសាបារាំង (អក្សរអង់គ្លេសរត់ពីក្រោម)

by **Jacques Perrin, Eric Deroo**, France/2011/86 min/VOFSTA

ដោយប្រើរូបភាពបណ្ណសារកម្រៗមកពីទូទាំងពិភពលោក លាយបញ្ចូលជាមួយអត្ថបទអក្សរសិល្ប៍ជាភាសាវៀតណាម បារាំង និងអង់គ្លេស ខ្សែភាពយន្តនេះបង្ហាញអំពីប្រវត្តិសាស្ត្រដ៏គួរឱ្យទាក់ទាញ តែពោរពេញដោយការឈឺចាប់របស់ប្រទេសវៀតណាមចាប់តាំងពីសម័យអាណានិគមរហូតដល់ការដួលរលំទីក្រុងសៃហ្គន។ **Jacques Perrin** ដែលជាអ្នកថតភាពយន្តឯកសារជនជាតិបារាំង បានដឹកនាំផលិតភាពយន្តខ្នាតវែងដ៏ក្តុកក្តួល លន្លង់លន្លោច ស្តីអំពីដំណើរដ៏វែងឆ្ងាយរបស់ប្រទេសវៀតណាមឆ្ពោះទៅកាន់ឯករាជ្យភាព។

With never-before-seen archived footage from all over the world, accompanied by texts from Vietnamese, French and American literature, this documentary explores Vietnam's fascinating yet painful history, from its colonization to the fall of Saigon. French documaker Jacques Perrin made a poignant, poetic found-footage feature on Vietnam's long march toward independence.

ព្រះអង្គម្ចាស់ និងទំនាយ
THE PRINCE AND THE PROPHECY

ដោយ ជីរ៉ានដ៍ ជេមស៍, អូស្ត្រាលី/១៩៨៨/៧៩នាទី (ជាភាសាអង់គ្លេស)

by James Gerrand, Australia/1988/79 min (English version)

ដើម្បីស្វែងយល់ពីសហសម័យក្នុងប្រទេសកម្ពុជា ខ្សែភាពយន្តនេះបានជីកកកាយយ៉ាងស៊ីជម្រៅចូលទៅក្នុងឫសគល់នៃវប្បធម៌ខ្មែរ និងជម្លោះតាមរយៈការឆ្លុះបញ្ចាំងអំពី៖ ឥទ្ធិពលនៃអាណានិគមបារាំង និងការតស៊ូទាមទារឯករាជ្យក្នុងតំបន់ឥណ្ឌូចិន បន្ទាប់ពីសង្គ្រាមលោកលើកទី២ ភាពភ័យខ្លាច និងការតបតទៅនឹងការឈ្លានពានពីសំណាក់វៀតណាមដែលជាប្រទេសជិតខាង។ រឿងនេះបង្ហាញពីការគ្រប់គ្រងរបស់សម្តេចនរោត្តម សីហនុ ភាពអំណត់របស់ទ្រង់ដើម្បីសន្តិភាព និងសំណល់សង្គ្រាមនៅក្នុងប្រទេសកម្ពុជា។

To understand contemporary Cambodia, this film delves into the roots of its culture & conflicts: it looks back to the impact of colonization by France and the struggle for independence in Indochina after the Second World War, the fears and the response to the thrust of their Vietnamese neighbors. It explores the years of Prince Norodom Sihanouk's rule, his juggle for peace, and traces Cambodia's destruction during the war.

កងអនុសេនាតូច Anderson
THE ANDERSON PLATOON

ដោយ ព្យែរ ស្ហ៊ីដូហ្វឺរ៍, បារាំង/១៩៦៧/៦០នាទី

by Pierre Schoendoerffer, France/1967/60 min

"កងអនុសេនាតូច **Anderson**" ជាភាពយន្តឯកសារថតដោយ **Pierre Schoendoerffer** ដែលជាអ្នកថតភាពយន្តសង្គ្រាម និងជាអតីតយុទ្ធជនបារាំងក្នុងសង្គ្រាមឥណ្ឌូចិនទី១។ ភាពយន្តនេះបង្ហាញអំពីសង្គ្រាមវៀតណាម ហើយអ្នកថតបានដាក់ចំណងជើងរឿងនេះតាមឈ្មោះមេរបស់គាត់ គឺលោកអនុសេនីយ៍ទោ **Joseph B. Anderson**។

The Anderson Platoon is a documentary by the French war cameraman and first Indochina War veteran Pierre Schoendoerffer about the Vietnam War, named after the leader of his platoon - Lieutenant Joseph B. Anderson.

បន្ទប់លាងហ្វីលរបស់ឃួង មី
THE DARKROOM OF KHUONG ME

ដោយ សាមុយអែល អូបាំង, បារាំង/២០០២/៦០នាទី

by Samuel Aubin, France/2002/60 min

ឃួង មី កើតក្នុងឆ្នាំ១៩១៥ គឺមានផ្ទុកប្រវត្តិសាស្ត្រនៃបដិវត្តភាពយន្តវៀតណាមពេញខ្លួន។ អំឡុងសម័យសង្គ្រាមឥណ្ឌូចិនលើកទី១ គាត់បានផលិតភាពយន្តឯកសារ និងភាពយន្តប្រឌិតជាច្រើន ដែលបំផុសគំនិតស្នេហាជាតិ។ ខ្សែភាពយន្តបែបជីវប្រវត្តិនេះគឺមានដាក់បញ្ចូលបទសម្ភាសន៍នានានៅទីក្រុងសៃហ្គន និងឈុតដកស្រង់ចេញពីខ្សែភាពយន្តចាស់ៗរបស់គាត់។

Khuong Mê, born in 1915, embodies the history of revolutionary Vietnamese cinema. During the heroic times of the First Indochina War, he produced documentaries and fictions of patriotic inspiration. This portrait articulates interviews conducted in Saigon and excerpts from his films.

ភ្លឺភ្នែក
LES YEUX BRÛLÉS

ដោយ ឡូរ៉ង់ រ៉ូត, បារាំង/១៩៨៦/៥៨នាទី

by Laurent Roth, France/1986/58 min

ស្ត្រីវ័យក្មេងម្នាក់មកយកកេសអាហារកងទ័ពដែលគេផ្ញើមកឱ្យនាង។ នៅក្នុងកេសនោះ សុទ្ធតែរបស់សេសសល់ និងរូបថតបន្សល់ទុកពីអ្នកថតរូបព័ត៌មានម្នាក់ឈ្មោះពេរ៉ូ ដែលបានបាត់ខ្លួននៅឌៀនបៀនភូ កាលពីថ្ងៃទី៨ ឧសភា ឆ្នាំ១៩៥៤។ នាងក៏ជជែកគ្នាជាមួយអតីតមិត្តរួមការងាររបស់ពេរ៉ូ ដូចជា**Raymond Depardon, Marc Flament, Pierre Schoendoerffer** ជាដើម។ តាមរយៈការចងចាំរបស់ពួកគេ រឿងរ៉ាវផ្សេងៗ និងរូបភាពជម្លោះនៃសតវត្សទី២០ ក៏ធ្វើឱ្យផុសចេញជាសំណួរមួយថាតើអ្វីទៅដែលនាំឱ្យមានរូបភាពនៃសង្គ្រាម។

A young woman collects a military canteen addressed to her. Inside effects and pictures from a photojournalist disappeared in Dien Bien Phu on May 8th, 1954. Then starts a discussion between the young woman and Péraud's formers colleagues, Raymond Depardon, Marc Flament, Pierre Schoendoerffer. Through the memories, stories and images of the twentieth century's conflicts current issues arise about what makes the image of war.

Pierre Schoendoerffer ៖ បុរស និងទុក្ខព្រួយ
PIERRE SCHOENDOERFFER, MEN AND SORROW

ដោយ ឡូរ៉ង់ រ៉ូត, បារាំង/២០១៨/៥៨នាទី

by Laurent Roth, France/2018/58 min

នៅក្នុងបទសម្ភាសន៍ធ្វើឡើងនៅឆ្នាំ១៩៨៦ ដោយ **Mireille Perrier** សមិទ្ធិករភាពយន្តដ៏ល្បី **Pierre Schoendoerffer** និយាយអំពីបទពិសោធន៍នៅឥណ្ឌូចិន នៅក្នុងរឿង ភ្លឺភ្នែក (**les yeux brûlés**)របស់ **Laurent Roth**។ ពេលនេះ អ្នកដឹកនាំរឿងរូបនេះអនុញ្ញាតឱ្យយើងបានស្តាប់បទសម្ភាសន៍ទាំងមូល ដោយពេលខ្លះមានទាំងបង្ហាញរូបភាពយឺតៗទៀតផង។

Interviewed in 1986 by Mireille Perrier, the famous filmmaker Pierre Schoendoerffer spoke of his experiences in Indochina in Les Yeux Brûlés by Laurent Roth. Today, Roth allows us to hear the entirety of the sound rushes from this canonical interview, with images sometimes worked in slow motion.

ARCHIVES SERIES FROM THE ECPAD

ដោយសហការជាមួយគ្រឹះស្ថានផ្សព្វផ្សាយ និងផលិតឯកសារសោតទស្សន៍នៃក្រសួងការពារជាតិបារាំង **(ECPAD) CIFF** នឹងនាំមកជូននូវបណ្ណសារកម្រៗពីប្រទេសកម្ពុជា និងតំបន់ទាំងមូល ដែលត្រូវបានផលិតឡើងដើម្បីបង្ហាញអំពីជីវិតប្រចាំថ្ងៃ ឬក៏កម្មវិធីផ្លូវការនានា។ កម្មវិធីបណ្ណសារនេះមានតែភាសាបារាំងប៉ុណ្ណោះ។

In partnership with the Defense Communication and Audiovisual Production Center (ECPAD*) CIFF is presenting series of rare footage from Cambodia and the region produced to document everyday life or official activities. Archives programs are in french language only but can be enjoyed to discover Cambodia 70 years ago.

ឯករាជ្យកម្ពុជាទសវត្សឆ្នាំ១៩៥០

1950s CAMBODIA INDEPENDENCE - ECPAD ARCHIVES

បទយកការណ៍ខ្លីៗបង្ហាញពីសម័យឯករាជ្យ ៖ ១.ចលនាដើម្បីឯករាជ្យប្រឆាំងនឹងវត្តមានបារាំងនៅក្នុងតំបន់ ២.ឯករាជ្យជាតិនៃកម្ពុជា

Short reports documenting the independence period: 1- Independence movement contest French presence in the region 2- The Independence of Cambodia

Copyright: [©Jean Delorme/SCA/ECPAD/Défense/SCA 82] [© Am Rong/ECPAD/Défense/FT680]

បណ្ណសារស៊េរីទី១ កម្ពុជាទសវត្សឆ្នាំ១៩៥០

ARCHIVES OF CAMBODIA IN THE 50'S - ECPAD

ឯកសារខ្លីៗបង្ហាញពីប្រទេសកម្ពុជា ឆ្នាំ១៩៥៣ និងឆ្នាំ១៩៥៤ រួមមាន ១.ប្រពៃណីកម្ពុជា ២.ទីក្រុងធំ ៣.រូបភាពពីអង្គរ ៤.ភ្នំពេញ ៥.បុណ្យអុំទូកនៅទីក្រុងភ្នំពេញ

Short document featuring Cambodia in 1953 and 1954 including: 1- Cambodian traditions 2- The Great Town 3- Images of Angkor 4- Phnom Penh 5- Phnom Penh Water Festival.

Copyright: [1- ©Unknown director/SCA/ECPAD/Défense/SCA 61] [2- ©René Rouy/ SCA/ECPAD/Défense/SCA 65] [3- ©René Rouy/ SCA/ECPAD/Défense/SCA 67] [4- ©Réalisateur inconnu/SCA/ECPAD/Défense/SCA 73] [5- ©Réalisateur inconnu/ SCA/ECPAD/Défense/SCA 77].

បណ្ណសារស៊េរីទី២ កម្ពុជាទសវត្សឆ្នាំ១៩៥០

ARCHIVES OF SE ASIA IN THE 50'S - ECPAD

ភាពយន្តផ្ទាល់ខ្លួនថតនៅចន្លោះឆ្នាំ១៩៤៨ និងឆ្នាំ១៩៥៤ ដោយកាពីទែន Hugues Bedetti អំឡុងពេលគាត់ធ្វើដំណើរ។

A personal documentary by Captain Hugues Bedetti filmed between 1948 and 1954 with the filmmaker's own commentary.

Copyright: [©Hugues Bedetti/fonds Hugues Bedetti/ECPAD/Défense/FA 13]

About ECPAD
The Defense Communication and Audiovisual Production Center (ECPAD) is a leading archive and audiovisual production centre. As such, it preserves exceptional collections of audiovisual and photographic archives that bear witness to more than one hundred years of history since the First World War, i.e. 15 million photos and 100,000 hours of films. Numerous archives can be accessed through the website: https://imagesdefense.gouv.fr

RÉPUBLIQUE FRANÇAISE
Liberté
Égalité
Fraternité

ecpad
IMAGES DÉFENSE

បណ្ណសារ ៖ ខួប៤០ឆ្នាំនៃឯករាជ្យជាតិកម្ពុជា

ARCHIVES: 40 ANNIVERSARY OF CAMBODIA INDEPENDENCE

ដោយ រីណេ ស្មីត, កម្ពុជា-បារាំង/១៩៩៣/១២៦នាទី

by Rene Schmitt, Cambodia, France/1993/126 min

នៅថ្ងៃ៩ វិច្ឆិកា ១៩៩៣ កម្ពុជាបានប្រារព្ធខួប៤០ឆ្នាំនៃបុណ្យឯករាជ្យជាតិ ដោយមានវត្តមានអ្នកការទូតជាតិ និងអន្តរជាតិចូលរួម។ នេះជាព្រឹត្តិការណ៍លើកដំបូងក្រោយរបបខ្មែរក្រហម។ នៅក្នុងខ្សែភាពយន្តនេះ ក៏មានបញ្ចូលការសម្តែងរបស់សិល្បករនៅរោងមហោស្រពសុរាម្រិត ដែលបង្ហាញអំពីប្រវត្តិសាស្ត្រកម្ពុជាផងដែរ។ បន្ទាប់មក គឺជាដំណើរកម្សាន្តទៅតំបន់ទេសចរណ៍នានា នៅក្នុងខែវិច្ឆិកា ១៩៩៣។

On November 9, 1993, Cambodia celebrated again the 40th anniversary of national independence, the first celebration after Khmer Rouge regime in the presence of the nation and international diplomats. The documentary also features a play that chronicles the history of Cambodia. The play is performed by artists at the Suramarit Theater. Next is a trip to various tourist destinations in Cambodia in November 1993.

SCARY WORLD

កោះពូលូ

PULAU, THE ISLAND

ដោយ អ៊ីយូ ហូ, ម៉ាឡេស៊ី/២០២៣/១១១ នាទី

by Eu Ho, Malaysia/2023/111min

វិស្សមកាលរបស់យុវវ័យមួយក្រុមប្រែក្លាយទៅជាសុបិនដ៏អាក្រក់មួយ បន្ទាប់ពីការចាញ់ភ្នាល់ដែលបង្ខំឲ្យពួកគេទៅគេងនៅលើកោះដែលត្រូវបានបោះបង់ចោលមួយយប់។ ដោយមិនដឹងខ្លួន, ពួកគេបានបំបែកមន្តអាគមន៍បុរាណមួយដែលគេបានដាក់ដើម្បីឃុំវិញ្ញាណនៅលើកោះនោះ។ ផ្លូវចេញតែមួយគត់ស្ថិតក្នុងដៃស្ត្រីម្នាក់និងសមត្ថភាពអរូបីរបស់គេដែលអាចដោះស្រាយប្រវត្តិសាស្ត្រស្នេហាឆ្លងវប្បធម៌ដ៏ព្រឺព្រួចបាន។

The vacation of a group of youngsters turns into an endless horrifying nightmare after a losing bet, forcing them to spend a night at a deserted island.They accidentally break an old spell that was placed to restrain a spirit trapped in the island. The only way out is in the hands of a girl and her supernatural gift to untangle an unsettling history connected to a tainted cross-cultural love story.

ថ្នាក់ ១២ង

12E

ដោយ លៀក លីដា, កម្ពុជា/២០២៣/៨៦នាទី

by Lyda Leak, Cambodia/2023/86 min

នៅឆ្នាំ 2013 សិស្សស្រីម្នាក់ឈ្មោះ **Adele Wilson** ជាសិស្សរបស់អង្គការក្រៅរដ្ឋាភិបាលមួយកន្លែងបានបង្កើតកូនដោយខ្លួនឯងរួចក៏សម្លាប់ខ្លួននៅក្នុងថ្នាក់ទី១២ងនោះ។ នៅឆ្នាំ 2022 អ្នកគ្រូរ៉ាវីជាគ្រូបង្រៀនថ្មីប្រចាំតំបន់ និងលោកឌីជាប៉ូលីសថ្មីប្រចាំតំបន់បានរួមគ្នាស៊ើបអង្កេតអំពីបណ្តាសានៅថ្នាក់ទី១២ងនោះ។

In the year 2013, Adele Wilson, an NGO student, gave birth on her own in classroom 12E and committed suicide immediately after. In 2022, Ravy, a new teacher and Dy, a new police officer, both new in the area, work together to investigate the curse of the 12E classroom.

កំណើតអរូប
THE RITUAL: BLACK NUN

ដោយ សែម វិសាល, កម្ពុជា/២០២៣/១០៥ នាទី

by Visal Sem, Cambodia/2023/105 min

ហ្គេប្រៀល ជាជនបរទេសកំពុងរស់នៅក្នុងខេត្តសៀមរាប បានប្រព្រឹត្តិកំហុសដ៏ធំមួយដែលបណ្តាលឲ្យស្ត្រីមានផ្ទៃពោះម្នាក់ស្លាប់។ ជាការសងសឹក ប្តីរបស់ស្ត្រីម្នាក់នោះបានដាក់បណ្តាសាលើ ហ្គេប្រៀលនិងប្រពន្ធរបស់គេ។ ក្រោយមកបណ្តាសានេះក៏ធ្លាក់ទៅលើកូនប្រសាររបស់ ហ្គេប្រៀល ឈ្មោះថា ស៊ីលវី ទៅវិញ។ ដើម្បីបញ្ចប់បណ្តាសានេះ ស៊ីលវី ត្រូវសម្រាលកូនដែល មិនទាន់កើតនោះដោយវិធី វះកាត់ដោយដៃរបស់អ្នកដាក់បណ្តាសាផ្ទាល់តែម្តង។

Gabriel, an expat living in Siem Reap makes a major mistake which leaves a pregnant woman dead. As revenge, the woman’s husband performs a magical ritual on Gabriel and his wife. This cursing spell later befalls Gabriel’s daughter-in-law, Sylvie. For the husband’s magical ritual to be completed, Sylvie must give life to the unborn child by a surgical birth by the spellmaker’s own hand.

អាថ៌កំបាំងព្រៃមរណៈ
IT’S IN THE WOOD

ដោយ ហ៊ីដេអុ ណាកាតា, ជប៉ុន/២០២២/១០៧ នាទី

by Hideo Nakata, Japan/2022/107min

សាច់រឿងបានកើតឡើងនៅក្នុងព្រៃពិតប្រាកដ ដែលគេជឿថា មានរឿងអភិនីហារ។ ភាពយន្តបែបរន្ធត់ជំនាន់ថ្មីនេះ គឺផ្អែកតាមការរៀបរាប់របស់មនុស្សដែលបានឃើញ «វា» ហើយនិងភាពអាថ៌កំបាំងដែលតួអង្គបានជួបប្រទះ។

Set in an actual forest said to be rife with supernatural phenomena, this next-gen horror film is based on witness accounts of people who saw “It” and the protagonists’ encounter with the mysterious “It”.

ខេអេហ្វស៊ី
KFC

ដោយ ឡេ ប៊ិញ ហ្សាំង, វៀតណាម/២០១៧/៦៩នាទី

by Lê Bình Giang, Vietnam/2017/69min

ភាពអាក្រក់សាហាវយង់ឃ្នងមានពិតមែន។ ដោយវាកើតមាននៅទីក្រុងហាណូយ ក្នុងផ្ទះដែលត្រូវបានគេផ្លាស់ប្តូរផ្នែកខ្លះៗទៅជាសាលសម្រាប់ធ្វើការវះកាត់ធ្វើទារុណកម្ម។ នៅទីនេះអ្នកជំងឺត្រូវបានកាត់ជាដុំតូចៗសម្រាប់បរិភោគ ហើយសាកសពទាំងនោះត្រូវបានដុកទ័រដែលស៊ីសាច់មនុស្សរួមជាមួយអ្នកជំនិតរបស់គាត់ចាប់រំលោភ។ ឥឡូវកូនប្រុសដែលមានរាងធាត់របស់គាត់ ក៏ញៀននឹងរសជាតិនៃសាច់មនុស្ស ហើយក្លាយជាមិត្តជាមួយនឹងកូនស្រីពេស្យាដែលធ្លាប់ជាជនរងគ្រោះរបស់ពេទ្យដ៏ព្រៃផ្សៃនេះ។ អំពើហិង្សាដ៏អសីលធម៌នេះត្រូវបានបន្តពីមួយជំនាន់ទៅមួយជំនាន់។ វដ្តនៃភាពព្រៃផ្សៃនេះនឹងកើតឡើងវិលជុំមិនចេះចប់។

Pure evil exists. It lives in Hanoi, in a small house that has been partly converted into an operating-theatre-cum-torture-chamber. Here, patients are cut up into bite-size pieces and posthumously raped by a cannibalistic doctor and his taciturn sidekick. His fat son, now also addicted to the taste of human flesh, befriends the children of a prostitute who fell victim to the deadly doctor. This amoral violence is inevitably passed on to the next generation. A cycle of cruelty is set in motion.

សាច់ញាតិ
NEXT OF KIN

ដោយ ថូនី វីលៀមស៍, អូស្ត្រាលី/១៩៨២/៨៩ នាទី

by Tony Williams, Australia/1982/89min

នៅក្នុងមណ្ឌលចាស់ជរាមួយកូនស្រីម្នាក់អានសៀវភៅកំណត់ហេតុរបស់ម្តាយគេ។ ក្រោយមក រឿងដែលបានកើតឡើងនៅក្នុងសៀវភៅកំណត់ហេតុនោះក៏ចាប់ផ្តើមកើតឡើងមកលើកូនស្រីវិញម្តង។

In a rest home for elderly people, a daughter reads her mother’s diary. Soon events that are mentioned in the mother’s diary begin to happen to the daughter.

អមតៈ
UNDEAD

ដោយ មែខល និង ភីធើ ស្ពៀរីក, អូស្ត្រាលី/២០០៣/៩៧ នាទី

by Michael & Peter Spierig, Australia/2003/97min

ភូមិស្ទូចត្រីដ៏គួរឲ្យចាប់អារម្មណ៍និងពេញនិយមមួយនៅប្រទេសអូស្ត្រាលីត្រូវបានវាយលុកដោយអាចម៍ផ្កាយចម្លែកដែលធ្វើឲ្យប្រជាជននៅទីនោះប្រែក្លាយទៅជាខ្មោចឆៅកាចសាហាវ, ចំណែកឯអ្នកដែលនៅរស់ត្រូវរកវិធីចាកចេញពីទីនោះ។

A quaint Australian fishing village is overcome by meteorites that turn its residents into the ravenous undead, leaving a small group of those unharmed to find a way out.

រលកចុងក្រោយ
THE LAST WAVE

ដោយ ភីធើ វា, អូស្ត្រាលី/១៩៧៧/១០៦ នាទី

by Peter Weir, Australia/1977/106min

មេធាវីនៅទីក្រុងស៊ីឌនីម្នាក់ការពារក្តីឱ្យជនជាតិដើមប្រាំនាក់ដែលជាប់ពាក់ព័ន្ធនឹងពិធីសាសនាឃាតកម្មហើយក្នុងអំឡុងពេលនោះ គេចាប់ផ្តើមដឹងអំពីរឿងចម្លែកៗរបស់ខ្លួននិងអំពីបុព្វហេតុដែលកើតឡើងក្នុងទីក្រុង។

A Sydney lawyer defends five Aboriginal Persons in a ritualized taboo murder and in the process learns disturbing things about himself and premonitions.

ព្រលឹងសោកសៅ
TAINTED SOUL

ដោយ ជីណានទី រ៉ូណា ទែមបាង អាស្រ៊ី, ឥណ្ឌូនេស៊ី/២០២២/១០៦ នាទី

by Ginanti Rona Tembang Asri, Indonesia/2022/106min

រ៉ាកាមានសមត្ថភាពពិសេសមួយដែលអាចនិយាយជាមួយខ្មោចដែលបានស្លាប់ទៅ។ គេប្រើសមត្ថភាពនេះដើម្បីបញ្ឈប់ព្រលឹងតៃហោងមួយដែលពោរពេញទៅដោយគំនុំជាមួយនឹងមិត្តរួមថ្នាក់របស់គេ, ហើយគេក៏ជួយព្រលឹងខ្មោចដ៏ស្រស់ស្អាតម្នាក់ស្វែងរកការចងចាំវិញផងដែរ។

Rakka has the ability to communicate with the dead. He uses his abilities to stop an evil spirit filled with vengeance against his schoolmates and helps a beautiful ghost to restore his memories.

ភាពភ័យខ្លាច
DEEP FEAR

ដោយ ហ្គ្រេហ្គោរី បេហ្គីន, បារាំង, បែលហ្ស៊ិក/២០២២/៨០ នាទី

by Grégory Beghin, France, Belgium/2022/80min

ដើមឆ្នាំ៩០នៅទីក្រុងប៉ារីស។ សិស្ស៣នាក់សម្រេចចិត្តទៅអបអរការបញ្ចប់ការសិក្សារបស់គេនៅកន្លែងរក្សាឆ្អឹងក្រោមដីមួយក្នុងទីក្រុងប៉ារីស។ នៅពេលដែលពួកគេរកឃើញរូងលាក់ខ្លួន៧១៧ដ៏ល្បីល្បាញ ពួកគេមិនដឹងទេថាវាមិនមែនជារូងតែមួយដែលទាហានអាល្លឺម៉ង់បន្សល់ទុកឡើយ។

Paris, the early 90s. Three students decide to celebrate their graduation with a visit to the Paris catacombs. When they discover the legendary 717 Bunker. Little do they know it's not the only thing Nazi soldiers have left behind them.

បាត់ខ្លួន
MISSING

ដោយ នីកូឡាស ឌី. ចនសិន, វីល មែរីក, សហរដ្ឋអាមេរិក/២០២៣/១១១ នាទី

by Nicholas D. Johnson, Will Merrick, United States/2023/111min

បន្ទាប់ពីការបាត់ខ្លួនរបស់ម្តាយគេ ក្មេងស្រីម្នាក់ព្យាយាមស្វែងរកម្តាយដោយប្រើប្រាស់អ្វីដែលគេមានតាមរយៈប្រព័ន្ធអនឡាញ។

After her mother goes missing, a young woman tries to find her from home, using tools available to her online.

MASTERS OF AFRICAN CINEMA

ការជ្រើសរើសជាពិសេសនូវខ្សែភាពយន្តអាហ្វ្រិកល្បីៗ និងទទួលបានពានរង្វាន់ ហើយដែលទទួលបានការកោតសរសើរពីសំណាក់អ្នកស្រឡាញ់ និងអ្នកវិភាគភាពយន្ត។ ភាពយន្តអាហ្វ្រិកមិនត្រូវបានចែកចាយ ឬផ្សព្វផ្សាយទូលំទូលាយទេ បើទោះបីវាមានការច្នៃប្រឌិត និងគុណតម្លៃខ្ពស់ក៏ដោយ។ កម្មវិធីនេះប្រមូលផ្តុំនូវស្នាដៃរបស់សមិទ្ធិករភាពយន្តធំៗ ដែលផ្តល់ការយល់ដឹងអំពីជីវិតរបស់ប្រជាជនអាហ្វ្រិក ការមុជចូលទៅក្នុងភាពសម្បូរបែបនៃជីវិតរស់នៅរបស់ពួកគេ។

សហការជាមួយវិទ្យាស្ថានបារាំង - ភាពយន្តអាហ្វ្រិក

A special selection of internationally acclaimed and awarded films from the African continent praised by film lovers and critics. African cinema is not well distributed, nor promoted, despite its high values and creativity.
This program gathers master directors providing insights into the lives of our African neighbours, a dive into their diversity, and an unstoppable need for spicing life with humour.

In partnership with the French Institute - Cinematheque Afrique

ក្មេងស្រីលក់ព្រះអាទិត្យ
THE LITTLE GIRL WHO SOLD THE SUN

ដោយ ជីប្រីល ឌីយ៉ូប ម៉ាមបេទី, សេណាហ្កាល់-បារាំង/១៩៩៩/៤៥នាទី

by Djibril Diop Mambéty, Senegal, France/1999/45 min

ក្មេងស្រីដើរជាមួយនឹងឈើច្រត់ម្នាក់ប្តេជ្ញាចិត្តធ្វើជាអ្នកលក់«ព្រះអាទិត្យ» នៅតាមផ្លូវដែលជាកាសែតថ្នាក់ជាតិរបស់សេណេហ្កាល់ ទោះជាមានការមិនពេញចិត្តពីក្មេងប្រុសៗជាច្រើនក្តី។ ជាសាច់រឿងនៃសេចក្តីក្លាហាន និងក្តីសង្ឃឹម ដឹកនាំដោយ **Djibril Diop Mambéty** សមិទ្ធិករភាពយន្តអាហ្វ្រិកដ៏ខ្លាំងក្លា និងលន្លង់លន្លោចម្នាក់។

A young girl on crutches is determined to be a street vendor of "Le Soleil," the national newspaper of Senegal, against the wishes of the other street boys. A tale of courage and hope directed by Djibril Diop Mambéty, one of the most powerful and poetic African filmmakers.

លុយ
THE FRANC

ដោយ ជីប្រីល ឌីយ៉ូប ម៉ាមបេទី សេណេហ្កាល់/១៩៩៤/៤៥នាទី

by Djibril Diop Mambéty, Senegal/1994/45min

ម៉ារីហ្គូ ជាតន្ត្រីករម្នាក់។ ម្ចាស់ផ្ទះជួលបានរឹបអូសឧបករណ៍តន្ត្រីរបស់គេដោយសារគេជំពាក់ថ្លៃផ្ទះ គេព្យាយាមយកវាត្រឡប់មកវិញ។ សន្លឹកឆ្នោតរបស់ម៉ារីហ្គូដែលជាប់ការយ៉ាងស្អិតនឹងទ្វារ ស្រាប់តែឈ្នះរង្វាន់ធំ គេក៏សម្រេចចិត្តលើកទ្វារទាំងមូលទៅកាន់ការិយាល័យលក់ឆ្នោត។

Marigo is a musician. Ever since his landlady confiscated his instrument to cover his rent, he tries to get it back. When his national lottery ticket, safely glued to his door, has the winning number, Marigo decides to carry the whole door to the lottery office.

បាល់មាស
THE GOLDEN BALL

ដោយ **Doukoure Cheik,** ហ្គីណេ-បារាំង/១៩៩៤/៩៣នាទី

by Doukoure Cheik, Guinea, France1994/93min

Bandian អាយុ១២ឆ្នាំ ជាក្មេងប្រុសអស្ចារ្យម្នាក់លើទីលានបាល់ទាត់។ មិត្តភក្តិតែងតែហៅគេថា ម៉ាស៊ីនម៉ាកូណូ (ម៉ាកូណូជាឈ្មោះភូមិដែលគេរស់នៅ)។ អំណោយបាល់ធ្វើពីស្បែក ដែល **Bandian** លាបថ្នាំពណ៌មាស ដូចជាវត្ថុទិព្វនោះ បាននាំរូបគេធ្វើដំណើរផ្សងព្រេងជាច្រើន។

Twelve-year old Bandian is a wonder on the soccer field. His friends call him the turbo Makono, named after the village where he lives. A gift of a leather ball, that Bandian paints gold, like a magical object brings him a series of adventures.





បញ្ញាលុយ
THE MONEY ORDER

ដោយ អ៊ូស្មាន់ សំបែន, សេណាហ្គាល់-បារាំង/១៩៦៨/១០៥នាទី

by Ousmane Sembène, Senegal, France/1968/105min

លុយសែកពីសាច់ញាតិម្នាក់នៅប៉ារីស បានធ្វើឲ្យជីវិតបុរសសេណេហ្គាល់ម្នាក់ក្រឡាប់ចាក់។ គាត់ត្រូវប្រឈមមុខនឹងអំពើពុករលួយ ភាពលោភលន់ សមាជិកគ្រួសារដែលមានបញ្ហា និងការផ្លាស់ប្តូរពីរបៀបរស់នៅបែបប្រពៃណីទៅជាទំនើបជាងមុន។ ខ្សែភាពយន្តដំបូងបង្អស់របស់ **Sembène** បង្ហាញពីការប្រសប់ក្នុងការប្រើភាពកំប្លែង និងភាពស៊ីជម្រៅរបស់គាត់ ចំពោះរឿងដ៏ក្តុកក្តួល។ រឿងនេះបានបើកភ្នែករបស់ពិភពលោកចំពោះទេពកោសល្យផ្នែកភាពយន្តរបស់អាហ្វ្រិក។

A money order from a relative in Paris throws the life of a Senegalese family man out of order. He deals with corruption, greed, problematic family members, the locals and the changing from his traditional way of living to a more modern one. Sembène's first feature film shows his masterful use of humor and his affinity for subtle, moving stories. The Money Order opened the world's eyes to Africa's cinematic talent.

សំឡេងខ្ញុំ
MY VOICE

ដោយ ហ្លូរ៉េស ហ្គោម៉េស, ហ្គីណេ ប៊ីសូ-បារាំង/២០០២/៩០នាទី

by Flores Gomes, Guinea Bissau, France/2002/90 min

គ្រួសាររបស់វីតាជឿថា មនុស្សស្រីណាច្រៀង នឹងស្លាប់។ នៅប្រទេសបារាំង វីតាក្លាយជាតារាអន្តរជាតិ។ នាងដឹងថា មិនយូរមិនឆាប់ម្ដាយនាងនៅអាព្រិចនឹងដឹងរឿងនេះមិនខាន ហើយគាត់ប្រាកដជាខឹង។ ដើម្បីដោះស្រាយបញ្ហា វីតាត្រឡប់ទៅភូមិកំណើតវិញ នាងរៀបចំចាត់ឆាកធ្វើជាស្លាប់ ហើយរស់ឡើងវិញ។

Vita's family is convinced that any woman who sings, will die. In France Vita becomes an international star. She realizes that sooner or later her mother in Africa will learn of the news and be furious. To solve this dilemma Vita goes back to her village and stages her own death and rebirth.



វ៉េបកាសាប្លង់កា
CASABLANCA BEATS

ដោយ ណាប៊ីល អាយូស ម៉ារ៉ុក-បារាំង/២០២១/១០១នាទី

by Nabil Ayouch, Morocco, France/2021/101 min

អាណា ជាអតីតអ្នកចម្រៀងវ៉េបម្នាក់ បានចូលបង្រៀននៅមជ្ឈមណ្ឌលវប្បធម៌នៃសង្កាត់ក្រខ្សត់មួយនៅក្នុងទីក្រុងកាសាប្លង់កា ប្រទេសម៉ារ៉ុក។ ដោយមានការលើកទឹកចិត្តពីគ្រូថ្មីនេះ សិស្សៗព្យាយាមដកខ្លួនឯងចេញពីគំនាបប្រពៃណី ដើម្បីរស់តាមចំណង់ចំណូលចិត្ត និងបញ្ចេញអារម្មណ៍ខ្លួនឯងតាមរយៈសិល្បៈហ៊ីបហប។

Anas, a former rapper, takes up a teaching job in a cultural center in an underprivileged neighborhood in Casablanca, Morocco. Encouraged by their new teacher, the students will try to free themselves from the weight of traditions to live their passion and express themselves through the art of hip hop.

STORIES OF THE WORLD

វិលវិញសេអ៊ូល
RETURN TO SEOUL

ដោយ ដេវី ជូ, បារាំង/កូរ៉េខាងត្បូង/កម្ពុជា/២០២២/១១៦ នាទី

by Davy Chou, France, South-Korea, Cambodia/2022/116 min

ដោយមានកម្លាំងចិត្តដើម្បីតភ្ជាប់ជាមួយនឹងដើមកំណើតរបស់នាងកញ្ញា ហ្វ្រេដឌី អាយុ២៥ឆ្នាំបាមត្រឡប់ទៅប្រទេសកូរ៉េខាងត្បូងជាលើកដំបូង ដែលជាទីកន្លែងកំណើតរបស់នាងមុននឹងត្រូវបានយកទៅចិញ្ចឹមនៅប្រទេសបារាំង។ នារីវ័យក្មេងដែលក្លាហានរូបនេះបានតាមស្វែងរកម៉ាក់ប៉ាបង្កើតនៅក្នុងប្រទេសមួយដែលនាងដឹងតិចតួចបំផុត ហើយនាំឲ្យជីវិតរបស់នាងទៅកាន់គោលដៅដែលថ្មីនិងនឹកស្មានមិនដល់។

On an impulse to reconnect with her origins, Freddie, 25, returns to South Korea for the first time, where she was born before being adopted and raised in France. The headstrong young woman starts looking for her biological parents in a country she knows so little about, taking her life in new and unexpected directions.

ឪពុក និងទាហាន
FATHER & SOLDIER

ដោយ ម៉ាថាយ វ៉ាឌីភី, សេណេហ្គាល់, ប្រទេសបារាំង/១៩៩៩/៤៥នាទី

by Mathieu Vadepied, Senegal, France/1999/45 min

អំឡុងពេល សង្គ្រាមលោកលើកទី១ លោកប៉ាម្នាក់បានចុះឈ្មោះចូលធ្វើជាទាហានបារាំងដើម្បីបាននៅជាមួយកូនរបស់គាត់ ដែលចូលធ្វើជាទាហានជំទាស់នឹងចិត្តរបស់គាត់។ នៅជួរខាងមុខ ពួកគេបានប្រយុទ្ធរួមគ្នានៅក្នុងអាណានិគមបារាំងនៅសេណាហ្គាល់។

During World War I, a father enlists himself in the French Army in order to be with his 17-year-old son who was recruited against his will. Sent to the front, they find themselves facing the war together in the French colony of Senegal.

ការថតចុងក្រោយ
FINAL CUT

ដោយ មីសែល ហាហ្សាណាវីស៊ីស, ប្រទេសបារាំង/២០២២/៩២ នាទី

by Michel Hazanavicius, France/2022/92 min

មានរឿងដ៏អាក្រក់កើតឡើងចំពោះផលិតកម្មភាពយន្តតូចមួយដែលខ្វះខាតថវិកាថតរឿងខ្មោចឆៅ ហើយពួកគេត្រូវបានវាយប្រហារដោយខ្មោចឆៅពិតប្រាកដ។

Things go badly for a small film crew shooting a low budget zombie movie when they are attacked by real zombies.

ភាពស្លូតត្រង់
THE INNOCENT

ដោយ ឡូវិស ហ្គារេល, បារាំង/២០២២/៩៩ នាទី

by Louis Garrel, France/2022/99mins

នៅពេលដែលអាប៊ែលដឹងថាម្ដាយរបស់គេត្រៀមនឹងរៀបការជាមួយនឹងបុរសដែលជាប់ពន្ធនាគារ គេបានភ័យជាខ្លាំង។ ជាមួយមិត្តភក្តិជិតស្និទ្ធម្នាក់ គេធ្វើគ្រប់យ៉ាងដើម្បីការពារម្ដាយ។ ប៉ុន្តែនៅពេលបានជួបចុងធ្វើឱ្យគេមានទស្សនៈថ្មីទៅវិញ។

When Abel learns that his mother is about to marry a man in prison, he freaks out. With the help of his best friend, he will do whatever it takes to protect her. But meeting his new stepfather may well offer him a new perspective.

IRAN WOMEN VOICES - SHORTS

កញ្ចក់
MIRROR

ដោយ **Faranak Moradi**, អ៊ីរ៉ង់/2021/14 នាទី
by Faranak Moradi, Iran/2021/14 min



ឆ្លងកាត់
PASS

ដោយ **Elika Abdollahi**, អ៊ីរ៉ង់/2020/10 នាទី
by Elika Abdollahi, Iran/2020/10 min

ស្រមោលនៃចចក
SHADOW OF THE FOX

ដោយ **Nooshin Meraji**, អ៊ីរ៉ង់/2022/11 នាទី
by Nooshin Meraji, Iran/2022/11 min



សក់ពណ៌ទង់ដែងស្រាល
ICE BLOND HAIR

ដោយ **Shabnam Gholikhani**, អ៊ីរ៉ង់/2021/9 នាទី
by Shabnam Gholikhani, Iran/2021/9 min

សូណា
SONA

ដោយ **Zahra Torkamanlou**, អ៊ីរ៉ង់/2022/15 នាទី
by Zahra Torkamanlou, Iran/2022/15 min



ការលាយគ្នា
MIXED

ដោយ **Mina Sadat Hosseini**, អ៊ីរ៉ង់/2022/11 នាទី
by Mina Sadat Hosseini, Iran/2022/11 min

មានផ្ទៃពោះ
PREGNANT

ដោយ **Golnaz Jamsheed**, អ៊ីរ៉ង់/2022/12 នាទី
by Golnaz Jamsheed, Iran/2022/12 min



សំណឹក
EROSION

ដោយ **Maryam Ghasemi**, អ៊ីរ៉ង់/2023/14 នាទី
by Maryam Ghasemi, Iran/2023/14min

EXPERIMENTAL SHORTS

ស្តាប់ឱ្យជិត
LISTEN CLOSELY

ដោយ ចច ហ៊ីរ៉ូកា ខ្លូក, ប្រទេសអង់គ្លេស/2022/9 នាទី
by George Hiraoka Cloke, United Kingdom/2022/9 min

អេឡិចត្រុងផ្លេកៗ
GLITTER ELECTRON

ដោយ ឈីរ៉ូ សាតូ, តាកាគី នូម៉ា, និង **E**
by Chihiro Sato, Takaaki Numa and E, Japan/2022/5 min

ប្រាប់អ្នកអំពី៖ បក្សីនិងសត្វឃ្មុំ
TELL YOU ABOUT: THE BIRDS AND THE BEES, SAGITTARIUS RISING

ដោយ ផូលីយ៉ាណា ផូប៉មេយ៉ឺ, ប្រទេសស៊ុយអែត/2022/15 នាទី
by Pollyanna Popermajer, Sweden/2022/15 min



ទីបញ្ចប់នៃសង្គ្រាម
AN END TO WAR

ដោយ សម៉ូន ម៉ាសស៊ី, ប្រទេសអ៊ីតាលី/2022/5 នាទី
by Simone Massil, taly/2022/5 min

រុក្ខជាតិតំបន់ត្រូពិច
TROPICAL PLANT

ដោយ តាណាគីត គីតសាណាយុងយ៉ុង, ប្រទេសថៃ/2021/17
by Tanakit Kitsanayunyong, Thailand/2021/17 min



ក្មេងតូចមហាក្ងរ
LITTLE SMASHER

ដោយ ជីល គូវែលីយេ, ប្រទេសបារាំង/2021/14 នាទី
by Gilles Cuvelier, France/2021/14 min

ការចងចាំនៃអនាគតកាល
MEMORIES OF TOMORROW

ដោយ ខារីនា ចាប៊ីដូ, ប្រទេសហ្វីលីពីន/2022/13 នាទី
by Karina Jabido, Shievar Olegario, Philippines/2022/13 min

GLIMPSE OF CAMBODIA

រសជាតិអាថ៌កំបាំង
THE TASTE OF SECRETS

ដោយ សួន ហ្គីយ៉ូម, កម្ពុជា, បារាំង/២០២០/១០០ នាទី
by Guillaume Suon, Cambodia, France/2020/100 min

«រសជាតិអាថ៌កំបាំង»រៀបរាប់អំពីម្ដាយម្នាក់ដែលមិនព្រមនិយាយពីកុមារភាពដ៏ជូរជត់របស់គាត់នាអំឡុងពេលប្រល័យពូជសាសន៏កម្ពុជា។ តូចចិត្តនឹងភាពស្ងៀមស្ងាត់របស់ម្ដាយ កូនប្រុសទាំងពីររបស់គាត់បានសម្រេចចិត្តដើរតាម **Antoine** ដែលជាចៅប្រុសរបស់អ្នកបានរួចជីវិតផុតពីប្រល័យពូជសាសន៏ **Armenain** ថតរូបខ្មោចដូនតារបស់គាត់នៅក្នុងតំបន់មជ្ឈិមបូព៌ា តាំងពីប្រទេសតួគី រហូតដល់ប្រទេសអ៊ីរ៉ាក់។

A mother refuses to speak about her childhood during the Cambodian genocide. Upset by her silence, her two sons decide to follow Antoine, a grandson of Armenian genocide survivors, photographing the ghosts of his ancestors in the Middle East, from Turkey to Iraq.

ស្តេចដូណាត់
THE DONUT KING

ដឹកនាំដោយ អាឡាយស៍ ហ្គូ, សហរដ្ឋអាមេរិច/២០២០/៩៤ នាទី
by Alice Gu, USA/2020/94 mins

រឿង«ស្តេចដូណាត់» រៀបរាប់អំពី រឿងរ៉ាវរបស់លោក**Ted** ដោយលាយឡំជាមួយជោគវាសនា ក្តីស្រឡាញ់ ការរស់រានមានជីវិត ជាពិសេសជីវិតដែលប្រឈមមុខនឹងការលំបាកតស៊ូពុះពារគ្រប់ឧបសគ្គ និង ភាពដែលត្រូវបានជួយ។ វាជារឿងដ៏កំសត់តែត្រូវបានផ្លាស់ប្តូរទៅជារឿងដែលមានន័យរមួយបស់ជនភៀសខ្លួនម្នាក់ដែលរត់គេចពីប្រទេសកម្ពុជា មកដល់សហរដ្ឋអាមេរិចនៅឆ្នាំ១៩៧៥ ហើយបានបង្កើតនំដែលមានតម្លៃរាប់លានដុល្លាហើយបានក្លាយជានំជាទីពេញចិត្តរបស់ជនជាតិអាមេរិច ហាងនំ**Donut Ted** បានឧបត្ថម្ភទិដ្ឋាការរាប់រយសម្រាប់ជនភៀសខ្លួនដែលនឹងចូលមក ហើយបានជួយពួកគេអោយក្រោកឈរនិងបង្រៀនពីវិធីនៃអាជីវកម្មនេះ។ នៅឆ្នាំ១៩៧៩ គាត់បានរស់នៅក្នុងសុបិនអាមេរិកាំង (**American Dream**) ប៉ុន្តែនៅក្នុងឆាកជីវិតមួយ រាសីឡើងត្រដែត ហើយវាក៏អាចធ្លាក់ចុះវិញដែរ។

Ted's story is one of fate, love, survival, hard knocks, and redemption. It's the rags to riches story of a refugee escaping Cambodia, arriving inAmerica in 1975 and building an unlikely multi-million-dollar empirebaking America's favorite pastry, the donutTed Sponsored hundreds of visas for incoming refugees and helped them get on their feet teaching them the ways of the donut business.By 1979 he was living the American Dream. But, in life, great rise can come with great falls.

បុប្ផាទេវី តួអប្សរាដំបូង
BUPPHA DEVI, THE FIRST ROYAL APSARA

ដោយ គ្រីស្តុហ្វ ហ្គាហ្វូឡូ, កម្ពុជា/២០២៣/៥២ នាទី
by Christophe Gargiulo, Cambodia/2023/ 52 min

ភាពយន្តឯកសារសម្តេចព្រះរាម«បុប្ផាទេវី តួអប្សរាទីមួយ»ជាការរៀបរាប់ វីដំណើរឆ្លងកាត់ពេលវេលាដែលរៀបរាប់ដោយព្រះអង្គម្ចាស់ក្សត្រី សម្តេចព្រះរៀម បុប្ផាទេវី។ អមដោយរូបភាពបណ្ណសារជាច្រើន ខ្សែភាពយន្តឯកសារនេះគឺជាបន្ទូលផ្ទាល់របស់ព្រះអង្គអំពីកុមារភាព ព្រះអយ្យកា ការចាប់ផ្តើមជាអ្នករបាំព្រះរាជទ្រព្យ ការថតភាពយន្តជាមួយលោកម៉ាកសែល កាមុយ សោកនាដកម្មខ្មែរក្រហម កិច្ចប្រឹងប្រែងជួយសង្គ្រោះរបាំព្រះរាជទ្រព្យ និងទស្សនវិស័យរបស់ព្រះអង្គចំពោះរបាំព្រះទ្រព្យសម័យទំនើប និងអនាគតរបស់របាំនេះ។

សហការផលិតដោយព្រះអង្គម្ចាស់ស៊ីសុវត្ថិ តេសូ និង **Allan Michaud** បកប្រែ និងអ្នករៀបចំអក្សររត់ពីក្រោម ដោយស៊ុន រ៉ាសី និងចាន់ លីដា

Buppha Devi - The First Royal Apsara is a journey through time narrated by Her Royal Highness Princess Buppha Devi. Illustrated by extensive archival footage, this documentary features the princess's own words about her childhood, her grandmother, her debut as a prima ballerina, her filming with Marcel Camus, the Khmer Rouge drama, her efforts to save the Royal Ballet and her vision of a modern Ballet and its future.

Produced in collaboration with HRH Tesso Sisowath, Allan Michaud
Translation and subtitling : Sun Rasey & Lida Chan

យើងពាក់មកុដ
WE WEAR THE CROWN

ដឹកនាំដោយ **Benjamin Rigley**, កម្ពុជា, ស្កុតឡេន/២០២២/៣៥ នាទី
by Benjamin Rigley, Cambodia, Scotland/2022/35 min

«យើងពាក់មកុដ»រៀបរាប់អំពីក្រុមបាល់ទាត់នារីភ្នំពេញក្រោន។ ភាពយន្តឯកសារនេះ លាតត្រដាងពីបញ្ហាដែលពួកគេប្រឈមមុខនៅក្នុងបរិយាកាសពោរពេញដោយការរងសម្ពាធនានា។ សូមចូលរួមសាវីន រ៉ុង និងស្រីរ័ត្នខណៈដែលពួកគេពុះពារដើម្បីក្តីស្រម៉ៃរបស់ពួកគេ ដើម្បីក្លាយជាកីឡាករបាល់ទាត់អាជីព។

We Wear The Crown follows the Phnom Penh crown's women's football team. Uncovering the challenges they face in an oppressed environment. Join Savin, Rong and Srey Rath as they fight for their dream to become professional football players.

គុនល្បុក្កតោរស់ឡើងវិញ
SURVIVING BOKATOR

ដោយ ម៉ាក បុចស្លើ, កាណាដា/២០១៨/៨៧ នាទី
by Mark Bochsler, Canada/2018/87 min

អ្នករស់រានមានជីវិតម្នាក់ពីរបបប្រល័យពូជសាសន៍ ស្រមៃចង់ធ្វើឱ្យកីឡាបុរាណមួយប្រភេទរស់ឡើងវិញ។ ក្តីស្រមៃនេះបានក្លាយទៅជាបេសកកម្មដ៏ល្អមួយដើម្បីជួយព្យាបាលជាតិខ្មែរ។ គ្រូគុនមួយរូបបានដឹកនាំកូនសិស្សមួយក្រុម បំពេញបេសកកម្មនេះ និងយកជ័យជម្នះក្នុងការប្រកួតអន្តរជាតិនានា។ កាលពី៤០ឆ្នាំមុន គុនល្បុក្កតោស្ទើរតែនឹងត្រូវពួកខ្មែរក្រហមលុបបំបាត់ ហើយគ្រប់គ្នាខ្លាចថា គុននឹងត្រូវបាត់បង់។

A genocide survivor's dream to revive an ancient sport becomes an inspiring mission to heal a nation. An elder master leads a team of young proteges on a grassroots mission to revive an ancient martial art and win international competition. Like many of Cambodia's great traditions, Bokator was nearly eradicated by the Khmer Rouge over 40 years ago and was feared extinct.

ជីវិត៣ តន្ត្រីតែមួយ
THREE LIVES, ONE SOUL OF MUSIC

ដោយ សុខ ចាន់រ៉ាដូ, កម្ពុជា/២០២២/២៤ នាទី
by Chanrado Sok, Cambodia/2022/24 min

ខ្សែភាពយន្តឯកសារខ្នាតតូចមួយនិយាយអំពីបងប្អូនប្រុសបីនាក់ដែលកើតចេញពីឪពុកម្តាយជាតន្ត្រីករប្រពៃណី។ បងប្អូនប្រុសទាំងបីបានបង្កើតក្រុមតន្ត្រីរ៉ុកមួយដែលមានអាយុច្រើនជាងមួយទសវត្សរ៍ ហើយយើងនឹងតាមដានដំណើររបស់ក្រុមតន្ត្រីនេះតាំងពីចាប់ផ្តើមរហូតដល់បច្ចុប្បន្ននេះ។

A mini-documentary tells the story of three brothers born to parents who are traditional musicians. The three brothers formed a pop-rock band for more than a decade and we follow their band's journey from then till the present time.

អនាគតកម្ពុជា
CAMBODIAN FUTURES

ដោយ ឌូស្ដាំង ណាកាវហៃដឺ, សហរដ្ឋអាមេរិច/២០២២/១៧ នាទី
by Dustin Nakao-Haider, United States/2022/17 min

រឿង«អនាគតកម្ពុជា» រៀបរាប់ពីដំណើររឿងចុងភៅ **Ethan Lim** ដែលនៅទីក្រុងស៊ីហ្កាកូ ខណៈដែលគាត់បានបង្កើតមុខម្ហូបដែលបំផុសគំនិតដោយអ្នកមាន ប្រវត្តិសាស្រ្តដ៏ស្មុគស្មាញរបស់របស់កម្ពុជា។ ការធ្វើម្ហូបដែលឈ្នះពានរង្វាន់របស់លោក **Lim** ដែលបានស្រមៃថាម្ហូបខ្មែរនឹងអភិវឌ្ឍដល់ណា ប្រសិនបើគ្មានសង្គ្រាមស៊ីវិលផ្អាកវានោះទេ។ នេះគឺជាអនាគតនៃការធ្វើម្ហូប។

Cambodian Futures follows Chicago-based chef Ethan Lim as he creates vibrant dishes inspired by the rich, complex history of Cambodia. Lim's award-winning cooking imagines how Cambodian cuisine might have evolved had the civil war not paused its growth. This is Culinary Futurism!

សំឡេងមាស
GOLDEN VOICE

ដោយ ម៉ាស វ៉េរ៉ូន, សហរដ្ឋអាមេរិច/២០២២/១៨ នាទី
by Mars Verrone, United States/2022/18 min

រឿង«សំឡេងមាស» រៀបរាប់ពី៤០ឆ្នាំបន្ទាប់ពីរបបខ្មែរក្រហម បុរសកែភេទម្នាក់បានត្រឡប់មកភូមិដែលគាត់បានរួចរស់ជីវិតពីប្រល័យពូជសាសន៍ ហើយបានរកឃើញអព្ភូតហេតុដ៏ចម្លែកនិងសមាគមអ្នកកែភេទ រួមជាមួយនិងគូស្នេហ៍ក្នុងជីវិតរបស់គាត់។

Forty years after the Khmer Rouge regime, a transgender man returns to the village where he survived the genocide and miraculously found queer and trans community, including the love of his life.

សំឡេងជនមានពិការភាព
LIVING WITH DISABILITY

ដោយសមិទ្ធិករភាពយន្តជាច្រើន, កម្ពុជា/២០២៣/៩០នាទី
by various filmmakers, Cambodia/2023/90 min

ជនមានពិការភាពតែងតែទទួលរងនូវផលប៉ះពាល់ផ្នែករាងកាយ និងស្មារតី។ ប៉ុន្តែនេះមិនមែនជាទីបញ្ចប់ សម្រាប់ពួកគាត់ឡើយ។ ពួកគាត់តស៊ូគ្រប់ឧបសគ្គគ្រប់បែបយ៉ាងក្នុងជីវភាពប្រចាំថ្ងៃរបស់ខ្លួន។ ភាពយន្តទាំងនេះឆ្លុះបញ្ចាំងពីជីវិតរបស់ជនមានពិការភាព មកពីសហគមន៍ផ្សេងៗ រួមទាំងក្រុមជនជាតិដើមភាគតិច នៃកម្ពុជា។ ដឹកនាំដោយសមិទ្ធិករភាពយន្តខ្មែរវ័យក្មេង៖ ខ្វះ ដោយ ព្រីង ព្រើល/ ពន្លឺក្នុងទីងងឹត ដោយ ជី រ៉ាឌី/ ខុសពីម្តាយខ្ញុំគិត ដោយ ចេន សុជាតា/ សុបិន្ត ដោយ កុប ពេជ្រ/ ដៃឆ្វេង ដោយ តែង ជី/ ផ្លូវឆ្ងាយ ដោយ ហៀម សុឃី/ នៅតែសង្ឃឹម ដោយ វ៉ន សាវង់។

People with disabilities have suffered physically and psychologically through their life experience. But it is not an end for them. They are struggling for their everyday lives. This film series feature stories of people different communities in Cambodia including indigenous communities: LACK by Pring Proel (13 min), LIGHT IN THE DARKNESS by Chey Rady (12min), OPPOSITE by Socheata Chen (20min), DREAM by Kob Pech (12min), LEFT ARM by Teng Chy (8min), WHEELCHAIR WANDERER by Heam Sokhy (10min), THE HOPE by Vorn Savong (17min)

ឆ្នាំទន្សាយ
YEAR OF THE RABBIT

ដោយ អាគីរ៉ា ម៉ូរីតា, កម្ពុជា/២០២៣/១២ នាទី
by Akira Morita, Cambodia/2021/12 min

វីដេអូឯកសារ«ឆ្នាំទន្សាយ»រៀបរាប់ពីដំណើររបស់អ្នករត់រ៉ឺម៉ក់កង់បីថ្លង់ម្នាក់ឈ្មោះ គង់ សុវណ្ណារ៉ូ គាត់ធ្វើដំណើរតាមផ្លូវដ៏មមាញឹកនៃក្រុងភ្នំពេញ ដើម្បីផ្គត់ផ្គង់គ្រួសាររបស់គាត់ដែលកំពុងតែលូតលាស់។ វាគឺជាការស្វែងរកក្តីស្រឡាញ់ វិធីផ្សេងនិងស្រដៀងគ្នាត្រូវបានបង្ហាញនៅក្នុង «ការស្តាប់» និង «ភាពថ្លង់» នៅក្នុងសហគមន៍ ហើយនៅក្នុងបណ្តាញគាំទ្រដែលលោក សុវណ្ណារ៉ូ បានបង្កើតនៅជុំវិញរូបគាត់។

Year of the Rabbit follows trailblazing deaf tuk-tuk driver Kong Sovannaro as he navigates the chaotic streets of Phnom Penh to support his growing family. It's an exploration of love; the different and similar ways it is expressed in the "hearing" and "deaf" communities; and across the network of support Sovannaro has created around himself.

ជីវិតផ្សេងទៀតរបស់ Kattia
THE OTHER LIVES OF KATTIA

ដោយ គ្រីស្តុហ្វ ហ្គាហ្គូឡូ, កម្ពុជា/២០២៣/២៦ នាទី
by Christophe Gargiulo, Cambodia/2023/26 min

ជារឿងរ៉ាវជីវិតរបស់លោកស្រីកេទីយ៉ា ហ៊ុយ ដែលជាប្រធានអង្គការមិនមែនរដ្ឋាភិបាលមួយឈ្មោះ **United for Cambodia Children's** តាំងពីពេលវេលាដំបូងៗនៃជីវិតរបស់គាត់រហូតដល់សព្វថ្ងៃ និងការតស៊ូរបស់លោកស្រី ដែលធ្លាប់ជាក្មេងស្រីខ្មែរតូចម្នាក់ត្រូវពួកខ្មែរក្រហមជម្លៀសចេញទៅជនបទ។

The story of Kattia Huy, President of the NGO United for Cambodia Children's,showing the early years of her life until today, dramas, other lives and the unwavering energy a Cambodian lady who was once little girl, thrown on the roads by the Khmer Rouge.

ក្រោមស្ពាន
UNDER THE BRIDGE

ដោយ អឿង បុណ្យសុវត្ថារី ញាន សាឡែន ឆុន ប៊ុនឆៃ, កម្ពុជា/២០២២/៦នាទី
by Bonsovathary Uoeung, Salen Nhean, Bunchhai Chhun, Cambodia/2022/6mins

លោកប៊ុនធឿនបានធ្វើការជាជាងកាត់សក់នៅខាងក្រៅផ្ទះជិត៣០ឆ្នាំមកហើយ។ វ័យរបស់គាត់ក៏ឈានដល់វ័យចំណាស់ គាត់នៅតែបន្តកាត់សក់ដែលមានទីតាំងក្រោមស្ពានដែលស្ថិតនៅជាយក្រុង។

Bunthoeun has been working as a barber at an outdoor space for almost 30 years. Aging towards senior life, he continues to give haircuts under a bridge located in the suburb.

ស៊ីនាង
SINEANG

ដោយ ខ្លូឌីន អូខែមប៉ូ, អូស្ត្រាលី/២០២២/៧ នាទី
by Claudine Ocampo, Australia/2022/7mins

ការអប់រំគឺជារឿងដ៏កម្រមួយសម្រាប់ក្មេងស្រីនៅតាមជនបទនៃប្រទេសកម្ពុជា, ដែលជាកន្លែង សៀប ស៊ីនាង ត្រូវជាកូនស្រីរបស់អ្នកដែល បានរួចផុតនិងរស់រានមានជីវិតពីសង្គ្រាមស៊ីវិលក្រីក្រមួយ។ ថ្វីត្បិតតែមានសមិទ្ធិផលសិក្សា និងវិជ្ជាជីវៈខ្ពស់ក៏ដោយ, ដំណើរកំណត់របស់ស៊ីនាង គឺជាជ័យជំនះលើការសង្ស័យលើខ្លួនឯង។

'ស៊ីនាង' ត្រូវបានផលិតឡើងដោយមានការគាំទ្រពី **Cambodia Rural Students Trust** និង **Swinburne University PAVE**។

Education is a rarity for girls in rural Cambodia where Sineang Seab, the daughter of poor civil war survivors grew up. Despite her high academic and professional achievements, Sineang's defining journey is a triumph over self doubt.

PHNOM PENH EVERYDAY LIFE Film Lab

Cambodia, 2023, 104 min

សមិទ្ធិករភាពយន្តដែលបានទទួលវគ្គបណ្តុះបណ្តាលជាលើកដំបូងដោយមជ្ឈមណ្ឌលធនធានសោតទស្សន៍ បុប្ផាណាក្រោមគម្រោង "ការបណ្តុះបណ្តាលជំនាញផលិតភាពយន្ត និងការលើកកម្ពស់ការផ្លាស់ប្តូរ ការសិក្សា និងវប្បធម៌តាមរយៈការផលិតភាពយន្តនៅកម្ពុជា"ដោយមានជំនួយឧបត្ថម្ភថវិកាពីមូលនិធិ **Henry Luce Foundation** បានចុះថតពីជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋរស់នៅក្នុងទីក្រុង និងជាយក្រុងភ្នំពេញ តាមរយៈការផលិតភាពយន្ត។

A series directed by young filmmakers trained by Bophana Center under the project "Training Tomorrow's Film Directors and Promoting Academic and Cultural Exchange through Cambodia's Filmmaking" funded by the Henry Luce Foundation explore the everyday life of Cambodian people in the city and suburb of Phnom Penh.

ស្ត្រីតូចដ៏អស្ចារ្យ
BIG LITTLE WOMEN

ដោយ ណាឌៀ ហ្វារ៉េស, អេហ្ស៊ីប/២០២២/៨៦ នាទី
by Nadia Fares, Egypt/2022/86 min

ស្ត្រីបីជំនាន់បានតវ៉ាប្រឆាំងនឹងការហាមឃាត់លទ្ធិបិតាធិបតី។ នៅក្នុងខ្សែភាពយន្តនេះ ណាឌៀ ហ្វារ៉េស ដែលជាអ្នកដឹកនាំរឿងជនជាតិស្វីសកាត់អេហ្ស៊ីប មានបំណងឧទ្ទិសរឿងនេះដល់ឪពុកនាង ខណៈដែលនាងរម្លឹកឡើងវិញអំពី៧៥ឆ្នាំនៃការតស៊ូឆ្លងកាត់ឧបសគ្គជាច្រើនរបស់ស្ត្រីទាំងនៅអេហ្ស៊ីប (ប្រទេសកំណើតឪពុកនាង) និងទាំងនៅស្វីស (ប្រទេសកំណើតម្តាយនាង)។

Three generations of women rebel against patriarchal prohibitions. In this cinematic letter, Swiss-Egyptian film director Nadia Fares pays tribute to her father as she recounts 75 years of women's struggles both in Egypt, her father's country, and in Switzerland, her mother's country, where she grew up.

រួមគ្នានិយាយ
SEW TO SAY

ដោយ រ៉ាកែល អាគីរ៉េ, អង់គ្លេស/២០២២/៦៩ នាទី
by Rakel Aguirre, United Kingdom/2022/69mins

ថាលៀ ជាអ្នកសិល្បៈគូរផ្ទាំងផ្សព្វផ្សាយម្នាក់ ដែលបានចូលជំរំស្ត្រីដើម្បីសន្តិភាពនៅដើមទសវត្សទី៨០ ដើម្បីប្រឆាំងនឹងអាវុធនុយក្លេអ៊ែ តាមរយៈការធ្វើសកម្មភាពអហិង្សា។ កាលពី៤១ឆ្នាំមុន នៅរដូវក្តៅឆ្នាំ១៩៨១ ស្ត្រី៣៦នាក់ចាកចេញពីផ្ទះ ហើយនាំគ្នាដើរពីកាឌីស (រដ្ឋធានីរបស់វ៉ើល) ឆ្ពោះទៅហ្គ្រីនហាំក្បែរក្រុងឡុងដ៏ ដើម្បីតវ៉ាប្រឆាំងនឹងកប៉ាល់មីស៊ីលអាមេរិក ដែលគេគ្រោងដាក់ពង្រាយនៅចក្រភពអង់គ្លេសជាផ្នែកមួយនៃការឆ្លើយតបនឹងសង្គ្រាមត្រជាក់។

Thalia is an artist and banner maker who, in the early 80s, joined a women-only peace camp to stand against nuclear weapons through non-violent action. 41 years ago, in the summer of 1981, a group of 36 women left their homes and marched from Cardiff, the capital of Wales, to Greenham Common near London to protest against the American Cruise missiles that were going to be deployed in the UK as part of the Cold War response.

ព្រះនាងតូច
BABY QUEEN

ដោយ យ័ន ប៊ីន ឡី, សិង្ហបុរី/២០២២/៦១ នាទី
by Yuan Bin Lei, Singapore/2022/61 min

រឿងព្រះនាងតូច បង្ហាញពីការតស៊ូ និងសេចក្តីរីករាយនៃការក្លាយជាមនុស្សមួយរូបដែលអ្នកចង់ រួមទាំងអត្ថន័យនៃការរកឃើញកន្លែងសុវត្ថិភាពនៅក្នុងសង្គមមួយដែលពេលខ្លះឃោរឃៅចំពោះអ្នកដែលមានភាពខុសគ្នាពីអ្នកដទៃ។ ខ្សែភាពយន្តនេះបង្ហាញពីការទទួលយកខ្លួនឯងនិងការរស់នៅខុសពីភាពធម្មតារបស់ខ្លួនថាជាសកម្មភាពនយោបាយផ្ទាល់ខ្លួន ប៉ុន្តែក៏ជាសកម្មភាពនយោបាយយ៉ាងជ្រាលជ្រៅផងដែរ។

Baby Queen illuminates the struggles and joys of becoming who you want to be, and what it means to carve out a safe space in a society that is at times cruel to those who are different. Candid and clear-eyed in its portrait of queer life, the film celebrates radical self-acceptance as a personal yet deeply political act.

ចាំ, ខ្ញុំមានសំណាង
YES, I'M LUCKY

ដោយ ម៉េលីស ដាទីហ្គ, បារាំង/២០២១/៧៤ នាទី
by Maylis Dartigue, France/2021/74 min

តាំងពីបានជួបជុំជាមួយគ្រួសាររបស់គេនៅប្រទេសស្រីលង្កាមក, ម៉េលីស ដាទីហ្គ កំពុងតែនឹងបង្កើតអត្តសញ្ញាណរបស់ខ្លួនរវាងប្រទេសពីរ និងវប្បធម៌ពីររបស់គេ។ តាមរយៈរឿងនិទាននៃដំណើរផ្តួចផ្តើមនេះ អ្នកផលិតភាពយន្តកំពុងស្វែងយល់ពីអ្វីដែលរឿងកូនចិញ្ចឹមរបស់គេបង្ហាញពីទំនាក់ទំនងផ្នែកខាងជើង-ផ្នែកខាងត្បូងនៅក្នុងពិភពលោករបស់យើង។

Since reuniting with her biological family in Sri Lanka, Maylis Dartigue is creating her identity between her two countries, her two cultures. Through the tale of this initiatory journey, the filmmaker is realising what her adoption story reveals of the North-South relations in our world.



មានតែស្រ្តីប៉ុណ្ណោះ
LADIES ONLY

ដោយ រ៉េបាណា លីស ចន, ឥណ្ឌា/២០២១/៨០ នាទី
by Rebana Liz John, India/2021/80 mins

ផលិតករភាពយន្តសួរសំណួរថា “តើអ្វីដែលធ្វើឲ្យអ្នកខឹង?”។ ក្រុមផលិតភាពយន្តតូចមួយចូលទៅក្នុងបន្ទប់មួយដែលមានតែស្រ្តីប៉ុណ្ណោះនៅលើរថភ្លើងមួយក្នុងទីក្រុងបុមបៃ។ ក្នុងពេលនោះ អ្នកស្គាល់គ្នាមួយចំនួនក៏ចូលរួមបញ្ចេញគំនិតរបស់គេរៀងៗខ្លួន, ការសារភាព នឹងរឿងរ៉ាវរបស់ពួកគេនៅទីសាធារណៈ។ ចម្លើយផ្សេងៗគ្នារបស់ពួកគេដាក់ពួកគេក្នុងស្ថានភាពមួយដែលលាតត្រដាងព័ត៌មានលម្អិត និងការសង្កេតដ៏គួរឲ្យចាប់អារម្មណ៍។

“What makes you angry?” asks the filmmaker. A small film crew enters the ladies compartments of the local trains in Mumbai. Chance encounters and acquaintances are invited to reveal their opinions, their confessions and their stories in a ‘public’ space. Their diverse answers thread themselves into an unfolding tapestry of details and observations. The light on the faces, the figures in the background, the driving noises of the train and the interaction of the travelers bring the space alive. Black and white images distill the essence of the space but keep us focused on the essentials: the women’s narrative. A poetic rhythm takes us across Mumbai and it’s mix of cultures, languages and faces, providing insight into how urban Indian women see and shape their lives. A feminist lens, explores what ambitions and freedoms mean for women in a hyper-industrial, wealth-driven and complex world.

ស្រ្តីរបស់ម៉ាលែក
MALEK’S GIRL

ដោយ អាម៉ាដ ខូដាឌី, អ៊ីរ៉ង់/២០២២/២៨ នាទី
by Ahmad Khodadi, Iran/2022/28mins

ម៉ាលែក ជាគ្រូបង្វឹកបាល់ទាត់នារីខ្នាតតូចម្នាក់ក្នុងទីក្រុងតូចមួយនៅប្រទេសអ៊ីរ៉ង់។ ទោះបីជាពួកគេជាផ្នែកមួយនៃលីកថ្នាក់ជាតិក៏ដោយ ក្រុមរបស់ពួកគេនៅតែជួបនឹងបញ្ហាហិរញ្ញវត្ថុដដែល។ ម៉ាលីក នៅតែប្តេជ្ញាចិត្តថានឹងធ្វើវាឲ្យបាន។

Malek is the coach of a women futsal team in a small city in Iran. Although they are part of the professional league, this team is struggling with financial problems. She is determined to do it at any costs.

អ្នកសុបិនអាហ្វហ្គានីស្ថាន
AFGHAN DREAMERS

ដោយ **David Greenwald**, សហរដ្ឋអាមេរិក/២០២២/៧២នាទី
by David Greenwald, USA/2022/72 min

ក្រុមផលិតមនុស្សយន្តមកពីអាហ្វហ្គានីស្ថានដែលមានសមាជិកសុទ្ធតែស្ត្រី ប្រឹងជម្នះឧបសគ្គដើម្បីជោគជ័យក្នុងការប្រកួតមនុស្សយន្តអន្តរជាតិ ស្របពេលដែលពួកនាងត្រូវតស៊ូប្រឆាំងនឹងវប្បធម៌បុរសនិយម និងការគំរាមកំហែងពីរបបគ្រប់គ្រងរបស់ពួកតាលីបង់។

Members of the all-girl robotics team from Afghanistan struggle to succeed in international competitions while combating their male-dominated culture and the threat of Taliban rule.

រដូវនៃការនេសាទ
THE CATCH

ដោយ **Che-chia Hsu,** តៃវ៉ាន់/២០២០/៥៥នាទី
by Che-chia Hsu, Taiwan/2020/55 min

ជារៀងរាល់ឆ្នាំ ចន្លោះខែវិច្ឆិកា និងខែកុម្ភៈ ជនជាតិដើមភាគតិចនៅតៃវ៉ាន់មួយក្រុមតែងធ្វើចំណាកស្រុកមកបោះជំរំក្បែរទន្លេឡានយ៉ាងនៅតំបន់ឆ្នេរភាគឥសានរបស់តៃវ៉ាន់។ ពួកគេធ្វើដំណើរពីឆ្ងាយមកទីនេះដើម្បីនេសាទអន្ទង់តូចៗប្រចាំរដូវ។ អំឡុងពេល៤ខែនេះ ជំរំនេះគឺជាផ្ទះរបស់ពួកគេ។

Each year, between November and the following February, a group of Indigenous Taiwanese migrant workers sets up camp near Lanyang River on the northeastern coast of Taiwan. They travel from afar to this spot in hopes of catching that season’s eel fry. For those four months, these camp sights are their homes.

អ៊ូមូអ៊ិ “អ្នកថែរក្សាប្រពៃណី”
UMUI “GUARDIANS OF TRADITIONS”

ដោយ ដានីញ៉ែល ឡូប៉េ, ជប៉ុន/២០២២/៧៥នាទី
by Daniel López , Japan/2022/75 min

ភូមិហ្គីណូហ្សានៅលើកោះអូគីណាវ៉ា - តោសុនកមួយក្បាលនៅចាំយាមការពារប្រជាជន និងបណ្តេញវិញ្ញាណអាក្រក់ចេញពីភូមិ។ អំឡុងពេលវាដើរល្បាតពេលមានជំងឺរាតត្បាតមួយ ពួកយើងក៏ប្រទះមនុស្សមួយចំនួនមកពីសម័យកាលខុសៗគ្នាដែលព្យាយាមថែរក្សាប្រពៃណីរបស់គេរៀងៗខ្លួន។ ពួកគេនឹងចែករំលែកក្តីស្រឡាញ់ដែលពួកគេមានចំពោះសិល្បៈប្រពៃណី ព្រមទាំងការលំបាកក្នុងការថែរក្សាមិនឱ្យវាបាត់បង់ផងដែរ។

Ginoza village on Okinawa island. A lion-dog watches over the village to protect the people and repel evil spirits.Through its wanderings in the middle of the pandemic, we meet inhabitants from different generations who try in their everyday life to keep traditions alive. They will share their love for traditional arts but also their struggle to protect them under the fear of seeing them disappear.

ខ្ញុំទ្រីលានដង ៖ ការផ្ទេរបន្ត
TRILLIONTH I: TRANSMISSION

ដោយ ភីធើ ជីន, កាណាដា/២០២២/៣៩ នាទី
By Peter Chin, Canada/2022/39 min

ខ្សែភាពយន្តកម្ពុជា-កាណាដាលំដាប់អន្តរជាតិមួយនេះ និយាយអំពីរបាំដែលថតនៅប្រទេសកម្ពុជា កាណាដា មិកស៊ិកូ អ៊ីតាលី និងឥណ្ឌូនេស៊ី។

A Cambodian-Canadian International dance film shot in Cambodia, Canada, Mexico, Italy and Indonesia.

តេឡូស
TELOS

ដោយ អាតស៊ូហ៊ីកូ វ៉ាតាណាប៊ី, បារាំង/២០២២/១៥ នាទី
by Atsuhiko Watanabe, France/2022/15 min

ស្រ្តីម្នាក់ដើរផ្សងព្រេងក្នុងទីក្រុងដែលបែកបាក់មួយដូចជាអ្នកគេងប្រមើល។ គាត់មានភាពភ័យខ្លាចយ៉ាងខ្លាំងដូចជាកំពុងស្ថិតនៅក្នុងសុបិនអាក្រក់។ យ៉ាងណាក្តី គាត់នៅតែរាំដូចជាគាត់កំពុងតែត្រូវសណ្តំក្នុងការចងចាំដ៏ល្អមួយអ៊ីចឹង។ បន្ទាប់មក គាត់ក៏ខ្សឹបដាក់ខ្យល់វេហាដូចជាកំពុងកោះហៅស្នេហ៍ដែលបានបាត់បង់ទៅ។ គាត់កំពុងតែនឹងជិតបាត់បង់សតិ ឈ្លក់វង្វេងនឹងសេចក្តីស្លាប់។ ការរាំបានជំរុញឲ្យគាត់ទៅដល់មហោស្រព តេឡូស ជាទីកន្លែងដែលគាត់ត្រូវបានច្រានទៅរកទីបញ្ចប់នៃពិភពលោករបស់គាត់។

A woman wanders like a sleepwalker in the ruins of a city. She is frightened as if being tormented by nightmares. However, she dances as if in a trance of a sweet memory. Then she whispers to the void, as if recalling the memory of a lost love. She is on the edge of madness, obsessed with death. The impulse of dance leads her to the theater of Telos, where she is driven into the endgame of her world.

សហសម័យបណ្តោះអាសន្ន
TEMPORARY CONTEMPORARY

ដោយ អូលីវើ ដេវីដ ប្រេន, ស្វីស/២០២២/១៤ នាទី
by Oliver David Brand, Switzerland/2022/14 min

គ្មានអ្វីអមតៈទេ។ ទោះបីជាទីកន្លែងមួយចំនួនដែលទំនងអាចនៅបានយូរអង្វែងក៏ដោយ។ សហសម័យបណ្តោះអាសន្ន សំដៅលើធម្មជាតិនៃភាពច្របូកច្របល់របស់ទីតាំងមួយចំនួនដែលមានសភាពបែបនោះក្នុងពេលថ្ងៃថតតែប៉ុណ្ណោះ។ ក្បាច់រាំដ៏មានថាមពល ទន់ភ្លន់ និងមានន័យយ៉ាងជ្រាលជ្រៅជារបស់អ្នកបង្កើតក្បាច់រាំ ហ៊្សូរ ចនណាថាន់។

Nothing is for eternity. Not even places that seem to outlast time. Temporary Contemporary is a moving testimony to the ephemeral nature of places that are in precisely that state only on the day the film is shot. The powerful, vulnerable and poetic choreographies are from choreographer Jonathan Hour.

BEAUTIFUL PLANET: EXPLORER

CIFF បាននិងកំពុងអភិវឌ្ឍឱ្យប្រសើរឡើងនូវកម្មវិធីពិសេសនេះ ដើម្បីផ្តោតលើការអប់រំផ្នែកបរិស្ថាន និងបម្រែបម្រួលអាកាសធាតុ ពីព្រោះការយល់ដឹងអំពីបញ្ហាពិតប្រាកដគឺមានសារៈសំខាន់សម្រាប់ឱ្យយើងផ្លាស់ប្តូរទម្លាប់ និងជួយសង្គ្រោះជីវៈចម្រុះដែលមនុស្សយើងត្រូវការចាំបាច់ ដើម្បីរស់រាននៅលើភពផែនដីដ៏ស្រស់ស្អាតនេះ។

ខ្សែភាពយន្ត និងកិច្ចពិភាក្សាលើប្រធានបទជាច្រើនត្រូវបានរៀបចំឡើង រួមមានការធ្លាក់ចុះនៃជីវៈចម្រុះ ធនធានទឹក ព្រៃទឹកភ្លៀង ការដឹកជញ្ជូន កសិកម្ម ថាមពល ការគ្រប់គ្រងទឹកនិងចំណីអាហារ ការប្រែប្រួលអាកាស ធាតុ ការបំពុល ប្រជាជនជនជាតិដើមភាគតិច...

នៅឆ្នាំនេះគឺផ្តោតជាពិសេសលើប្រធានបទ "តំបន់ទន្លេមេគង្គ" (ជាពិសេស ក្នុងផ្នែក"ស្វែងយល់អំពីទន្លេមេគង្គ") និង "ប្រជាជនជនជាតិដើមភាគតិច"។

CIFF has been developing this special section dedicated to environmental education and climate change, because understanding the issues is crucial for us to shift our ways and save the biodiversity that our Human kind needs to survive on this beautiful planet.

A selection of films and discussions on a diversity of topics that include: biodiversity loss, water resources, rainforest, transportation, agriculture, power, water and food management, climate change, pollution, Indigenous communities...

This year Beautiful Planet expands into worldwide topics (Explorer), a gathering on regional environement (Mekong Discovery) and indigenous communities in the region and around the world (Indigenous Voices).

ម៉ាម៉ូឌី អ្នកជីកដើមបៅបាប់ (Baobab) ចុងក្រោយ
MAMODY, THE LAST BAOBAB DIGGER

ដោយ ស៊ីរ៉ាលល៍ ខនូ, បារាំង/២០២២/៥០ នាទី
by Cyrille Cornu, France/2022/50 min

ខ្ពង់រាប **Mahafaly** ជាដីស្ងួតបែកក្រហែង ស្ថិតនៅភាគនិរតីប្រទេសម៉ាដាហ្គាស្ការ។ នៅទីនេះមានភ្លៀងធ្លាក់តែ ២ ទៅ ៣ ដងប៉ុណ្ណោះក្នុងមួយឆ្នាំ។ ក្នុងស្ថានភាពរស់នៅដ៏សែនលំបាកបែបនេះ អ្នកស្រុករស់នៅភូមិតូចមួយនៃ អាមប៉ូតាកា បានរកឃើញវិធីស្តុកទឹកចម្លែកមួយ។

In the southwest of Madagascar, the Mahafaly plateau is an extremely arid land. Here, the rains fall only a few times a year. In these very difficult living conditions, the inhabitants of the small village of Ampotaka found a unique solution to store water.

រោមសត្វ
REAL FUR

ដោយ ថៃម៉ូរ៍ ឈូដរ៉ាយ, កាណាដា/២០២២/៨៩ នាទី
by Taimoor Choudhry, Canada/2022/89 min

រោមសត្វ ធ្វើឲ្យយើងភ្លឺភ្នែកតាមរយៈការស៊ើបអង្កេតសម្ងាត់អំពីតម្លៃពិតនៃឧស្សាហកម្មចិញ្ចឹមសត្វយករោមនៅប្រទេសកាណាដា។ វាគឺជាដំណើររបស់អ្នកដឹកនាំរឿង **Taimoor Choudhry** ដែលបានផ្លាស់ប្តូរខ្លួនឯងពីអ្នកប្រើប្រាស់ដែលមិនមានការយល់ដឹងឲ្យក្លាយទៅជាសកម្មជនមួយរូបដែលមានចំណូលចិត្តក្នុងការសម្ភាសន៍ជាមួយអ្នកដឹកនាំផ្នែកសិទ្ធិរបស់សត្វ អ្នកបដិវត្ត មេធាវី អ្នកនយោបាយ និងតារាល្បីៗ ដោយកិច្ចខិតខំប្រឹងប្រែងដើម្បីធ្វើការផ្លាស់ប្តូរយ៉ាងពិតប្រាកដ។

Real Fur is an eye-opening undercover investigation about the true cost of the fur farming industry in Canada. It follows the journey of director Taimoor Choudhry as he transforms from being an uninformed consumer to a passionate activist through interviews with animal rights leaders, changemakers, lawyers, politicians and celebrities in an effort to make real change.

ពេលខ្លះ ច្រាំងសមុទ្រក៏អាចលង់ទឹកបានដែរ
SOMETIMES, EVEN THE SHORE DROWNS

ដោយ ម៉ាហេរ៉ា អូម៉ារ៍, ប៉ាគីស្ថាន/២០២២/១៧ នាទី
By Mahera Omar, Pakistan/2022/17 min

នៅចន្លោះជំនោរ និងលំនាច ទីក្រុងលាតត្រដាងឲ្យឃើញច្រាំងសមុទ្រដែលជាទីជម្រកនៃសត្វត្រីរំកិលនៅលើដី ក្តាមកំពុងតោងយ៉ាងជាប់ទៅនឹងគល់ដើមកោងកាង ខ្យងសមុទ្រ ក្តាមពពុះកំពុងពូនខ្សាច់ទៅជាដុំៗ កុកជើងវែងចាំចាប់ត្រីជាចំណី សត្វ **Curlew** ចាំឃ្លាំមើលក្តាម និងឧទរបាទសមុទ្រដែលស៊ីសាច់ជាអាហារដែលត្រូវបានគេស្គាល់ថាជាសិប្បីជាតិផងដែរ។

Between the ebb and flow of tides, the city's exposed shoreline is home to a fish that walks on land, the mud crab that clings tenaciously to mangrove tree trunks, the mighty periwinkle, the bubbler crab that spits out sand balls, the long legged egret that fishes, the curlew that stalks fiddler crabs, and the carnivorous marine gastropod mollusks, aka the nudibranchs.

ទន្លេក្រោមហ្ស៊កដានី
DOWN RIVER JORDAN

ដោយ អាឌី ណាវ៉ារ៉ូ, សហរដ្ឋអាមេរិក/២០២២/៦០ នាទី
by Addie Navarro, USA/2022/60 min

យើងដឹងស្រាប់ហើយថា ទន្លេហ្ស៊កដានីដើរតួយ៉ាងសំខាន់ក្នុងការបង្កើតសង្គមមនុស្ស ដោយការផ្តល់ទឹក និងដីមានជីជាតិសម្រាប់អរិយធម៌ដំបូងគេបង្អស់មួយចំនួន និងជាសាក្សីនៃការកកើត និងការដួលរលំអាណាចក្រ។
អស់ជាច្រើនសតវត្ស នៅខាងក្រោមជ្រលងភ្នំហ្ស៊កដានីជាកន្លែងធ្វើចំណាកស្រុកបក្សីដ៏ធំបំផុតក្នុងពិភពលោក ក៏ដូចជាទីជម្រកជីវសាស្ត្រចម្រុះ ដែលរុក្ខជាតិ និងសត្វនៃទ្វីបអាហ្វ្រិកខាងកើត និងអាស៊ីខាងលិចជួបគ្នា។

សព្វថ្ងៃនេះ ទន្លេនេះបានប្រាប់ពីរឿងនិទានផ្សេងៗគ្នាក្នុងការទ្រទ្រង់ជីវិត វាបានបើកកកាយពីរឿងរ៉ាវ ជម្លោះនយោបាយរាប់សហស្សវត្សរ៍របស់មនុស្សនៅពេលដែលស៊ីរី ហ្ស៊កដានី និងអ៊ីស្រាអែលយកធនធានចេញពីទន្លេហ្ស៊កដានីដោយគ្មានបទប្បញ្ញត្តិអន្តរជាតិ ឬហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងកាកសំណល់។ ភាពតានតឹងរវាងប្រទេសជាប់ទន្លេ និងកង្វះកិច្ចព្រមព្រៀងគ្រប់គ្រងទឹកពីត្រីភាគីបានអនុញ្ញាតឱ្យមានការទាញយកធនធានច្រើនហួសហេតុ ការអនុវត្តកាកសំណល់ដែលបង្កគ្រោះថ្នាក់ និងទំនោរក្នុងការបន្ទោសអ្នកដទៃជាជាងទទួលខុសត្រូវចំពោះសុខុមាលភាពទន្លេ។ ជាលទ្ធផលបានឃើញថា លំហូរទឹករបស់ទន្លេហ្ស៊កដានីបានថយចុះ ៩៦% ក្នុងរយៈពេលហុកសិបឆ្នាំចុងក្រោយ។

The Jordan River has played a major role in shaping human society as we know it, providing freshwater and fertile soil for some of the earliest civilizations and witnessing the rise and fall of empires. For centuries, the lower Jordan Valley has served as one of the largest bird migration sites in the world, as well as the biologically diverse sanctuary where the flora and fauna of the East African and West Asian continents come together.

Today, the river tells a different story from the life-giving tale it has told for a millennium revealing the devastating impact of human political conflict as Syria, Jordan, and Israel take from the Jordan River without international regulation or waste-management infrastructure. The tension between the riparian nations and the lack of a trilateral water management agreement has allowed for excessive extraction, harmful waste practices, and a tendency to assign blame to others rather than take responsibility for the river's well-being. As a result, the Jordan River has seen its water flow reduced by 96% over the last sixty years.

ជុំវិញទន្លេមេគង្គ
MEKONG DISCOVERY Days

ចូលរួមដោយឥតគិតថ្លៃ / FREE ADMISSION

• ការបញ្ចាំងភាពយន្ត • ការពិភាក្សា • ពិព័រណ៍រូបថត
• វេទិកាសំនួរចម្លើយ • បទបង្ហាញ

• Films Screenings • Panel discussions
• Photo Exhibitions • Forum • Presentations

«រុករក និងស្វែងយល់ពីបរិស្ថាន
និងប្រជាជននៅតំបន់ទន្លេមេគង្គ»

«Explore and understand the Environment
and the People of the Mekong region»

ទីតាំង ៖ អូឡាំព្យាម៉ល ជាន់ផ្ទាល់ដី
ចាប់ពីថ្ងៃពុធ ទី៣១ ខែឧសភា ដល់ថ្ងៃ ព្រហស្បតិ៍ ទី០១ ខែមិថុនា
ចាប់ពីម៉ោង ១០ព្រឹក ដល់ម៉ោង៦ល្ងាច

Venue: Olympia Mall ground floor:
Wed 31 May - 01 June, from 10 AM till 6 PM

BEAUTIFUL PLANET: MEKONG DISCOVERY

មេគង្គ ២០៣០
MEKONG 2030

ដោយ សុទ្ធោ គុល្លិការ, អានីសាយ កែវឡា, សៃ ញូ ខាម, អាណុឆា ស៊ូវីឆាកនពុង និង ផាម ង៉ុក ឡាន កម្ពុជា, ឡាវ, មីយ៉ាន់ម៉ា, ថៃ, វៀតណាម/២០១៩/៩៤ នាទី

by Kulikar Sotho, Anysay Keola, Sai New Kham, Anocha Suwichakornpong and Pham Ngoc Lan, Cambodia, Laos, Myanmar, Thailand, Vietnam/2019/94 min

មេគង្គ ២០៣០ ជាកម្រងភាពយន្តដែលផ្គុំឡើងដោយភាពយន្តខ្លីៗចំនួន៥ដែលប្រមើលមើលអនាគតនៃទន្លេមេគង្គដោយផ្អែកលើទស្សនវិស័យខុសៗគ្នា។ ដោយផ្តោតលើឆ្នាំ២០៣០ ភាពយន្តនេះមានគោលបំណងជាការកម្សាន្តអារម្មណ៍ ក៏ដូចជាជំរុញឲ្យទស្សនិកជនអភិរក្សទន្លេជីវិតដ៏សំខាន់មួយនេះ។

MEKONG 2030 is an anthology film comprising five short stories that envision the future of the Mekong River from different cultural perspectives.Set in the year 2030, the films aim to both entertain and inspire audiences to actively protect this critical life source.

ទឹកដីដែលបាត់បង់ទៅ
LOST LANDS

ដោយ អែនឌី បល, កម្ពុជា/១៤ នាទី

By Andy Ball, Cambodia/14 min

កំណើនតម្រូវការខ្សាច់នៅប្រទេសកម្ពុជាបណ្តាលឲ្យគ្រួសារពីរជួបនឹងផលវិបាកយ៉ាងធ្ងន់ធ្ងរអំឡុងពេលដែលប្រទេសកំពុងនឹងអភិវឌ្ឍយ៉ាងឆាប់រហ័ស។

Cambodia's insatiable appetite for sand leaves two families left to bear the consequences in the wake of the country's rapid development.

នៅទន្លេមួយ៖ បញ្ហានៅទន្លេមេគង្គ
ONCE UPON A RIVER: TROUBLE ON THE MEKONG

ដោយ សៀហ្សាដ ហាមីដ អាមាដ, សិង្ហបុរី/២០២១/៤៨ នាទី

by Shehzad Hameed Ahmad, Singapore/2021/48 min

ទន្លេមេគង្គត្រូវបានគេចាត់ទុកជាមាតានៃទន្លេទាំងអស់។ វាផ្តល់ផលទៅកាន់អ្នកចំការនិងអ្នកនេសាទចំនួន៨០លាននាក់ទូទាំងប្រទេសទាំងអស់ដែលវាហូរឆ្លងកាត់។ ប៉ុន្តែភាពតានតឹងកំពុងតែនឹងរីករាលដាលបន្ទាប់ពីការសាងសង់នៃទំនប់ទឹកមេគង្គលើដែលឧបត្ថម្ភដោយប្រទេសចិន បណ្តាលឲ្យមានបញ្ហាដូចជាភាពរាំងស្ងួត និងភាពលំបាកក្នុងការនេសាទតាមបណ្តាមេគង្គក្រោម។ ពួកយើងឆ្លងកាត់ប្រទេសកម្ពុជាដើម្បីស្វែងយល់អំពីតម្រូវការនៃសេដ្ឋកិច្ចលូតលាស់ដែលនឹងត្រូវរំពឹងកំណើនតម្រូវការថាមពលអគ្គិសនីនា២០ឆ្នាំខាងមុខនេះ។ តើការអភិវឌ្ឍន៍នេះនឹងផ្តល់ផលប៉ះពាល់អ្វីខ្លះដល់បរិស្ថាននិងប្រព័ន្ធទឹកនៅក្នុងតំបន់នោះ?

